# ខ្មែរមានពូជ

៙✺៚

ដោយ


លោក ស៊ុយ ស៊ាងហេង

លោក ចាយ សិរីវុឌ្ឍ

លោក ឌី ការ៉ែត

ភិក្ខុ ងិន ភេន

# ខ្មែរមានពូជ

៚✽៛

ដោយ

លោក ស៊ុយ ស៊ាងហេង

លោក ចាយ សិរីវុឌ្ឍ

លោក ឌី ការ៉េត

ភិក្ខុ ងិន ភេន

បោះពុម្ពចែកជាធម្មទាន

លើកទី ១ ចំនួន ១៥០០ ក្បាល

ដោយពុទ្ធបរិស័ទ វត្តពោធិវង្ស

ប្រទេសបារាំង

ព.ស. ២៥៥៣ គ.ស. ២០០៩

# អារម្ភកថា

៙❋៚

ខ្មែរយើងមិនមែនជាជាតិទើបនឹងកើតថ្មី និង មិនមែនជាជាតិគ្មានវប្បធម៌ទេ ។ យើងជាជាតិមួយមានប្រវត្តិយូរក្រៃលប្រើនពាន់ឆ្នាំណាស់មកហើយ ជាជាតិមួយខ្លាំងពូកែមានវប្បធម៌ អរិយធម៌ ចេះសាងប្រាសាទសីលាស្កឹមស្កៃ... សូម្បីតែពួកបរទេសក្នុងពិភពលោក ក៏កោតសរសើរ និង ស្ញប់ស្ញែងស្នាដៃខ្មែរយើងដែរ ។

ក្នុងពេលដែលខ្មែរយើងកំពុងចុះខិនថយខ្លាំងដូចសព្វថ្ងៃនេះ ខ្មែរអ្នកមិនបានរៀនសូត្រ មិនបានទទួលការអប់រំ មិនដឹងប្រវត្តិសាស្ត្រជាតិរបស់ខ្លួន កាលឃើញជាតិជិតខាងគេចំរើនគ្រាន់បើ សរសើរគេ លើកតម្កើងគេ និយមគេ ភ្លេចជាតិរបស់ខ្លួន អ្នកខ្លះមិនចង់ថាខ្លួនឯង ជាខ្មែរផង។ នេះ ជាកំហុសធ្ងន់ និង ជាគ្រោះថ្នាក់មួយដ៏ធំរបស់ជាតិខ្មែរយើង។

អាស្រ័យហេតុនេះ ខ្ញុំគិតរៀបចំសរសេរកូនសៀវភៅមួយ ស្តីពីខ្មែរមានពូជ ដើម្បីជួយរំលឹកកូនចៅខ្មែរ អំពីអរិយធម៌ និង ការអប់រំល្អនៃជាតិសាសន៍ខ្មែរ ប៉ុន្តែ ខ្ញុំកាន់តែចាស់ជរាណាស់ហើយ មិនដឹងជាខ្ញុំអាចសរសេរចប់ ឬ មិនចប់ ។ ម្យ៉ាងទៀត ខ្ញុំមិនមានចំណេះវិជ្ជាគ្រប់គ្រាន់ផង ក្នុងរឿងនេះ ។ ខ្ញុំគិតសាជាថ្មីថា បើធ្វើសិក្ខាសាលាមួយ អញ្ជើញលោក អ្នកចេះដឹងមកចូលរួមធ្វើ នឹងអាចកើតបានជាកូនសៀវភៅមួយយ៉ាងឆាប់ និងមានគុណភាពល្អប្រសើរផង ។ លុះគិតឃើញដូចនោះ ខ្ញុំចាប់រៀបចំធ្វើជាសិក្ខាសាលាមួយឡើង ។ កូនសៀវភៅដែលលោក អ្នក កាន់នៅដៃ នេះ

ជាលទ្ធផលនៃសិក្ខាសាលានោះ ។ ខ្ញុំសង្ឃឹមថា កូនសៀវភៅនេះ នឹងបាន ជាប្រយោជន៍ខ្លះ ដល់លោក អ្នក អាន និង ជាតិខ្មែរយើងជាពុំខាន ។

ខ្ញុំសូមឧទ្ទិសផលនៃសេចក្តីល្អ ដែលកើតពីកូនសៀវភៅនេះ ជូន ចំពោះវិញ្ញាណនៃបុព្វបុរសខ្មែរទាំងឡាយ ជូនចំពោះវិញ្ញាណនៃបុព្វការី របស់ខ្ញុំ របស់លោកវាគ្មិន របស់លោក អ្នក ចូលរួមសិក្ខាសាលា និង របស់លោក អ្នក ជួយឧបត្ថម្ភការបោះពុម្ពគ្រប់គ្នា ។ សូម បុព្វបុរស បុព្វការី របស់យើង អនុមោទនា ទទួលយកនូវឥដ្ឋមនុញ្ញផល ជាទីគាប់ ចិត្តនេះ កុំបីខាន ។

វត្តពោធិវង្ស ថ្ងៃទី ០១ សីហា ២០០៩

**ភិក្ខុ ខិន គេន**

# សេចក្តីអញ្ជើញ

ថ្ងៃអាទិត្យ ទី២៦ ខែមេសា ២០០៩ វេលាម៉ោង១៤.៣០ នៅវត្តពោធិវង្ស មានរៀបចំធ្វើសិក្ខាសាលាមួយ ស្តីពី **ខ្មែរមានពូជ** ។

ដឹកនាំការប្រជុំដោយ **ភិក្ខុ ពេជ្រ សាម៉ុន**

លោក អ្នក ធ្វើអន្តរាគមន៍ មាន ៤ រូប គឺ ៖

**១- លោក ស៊ុយ ស៊ាងហេង** **២- លោក ចាយ សិរីវុឌ្ឍ**

**៣- លោក ឌី ការ៉ែត** **៤- ភិក្ខុ ចិន គេន**

ក្នុងម្នាក់ៗ និយាយកុំឲ្យលើស ១៥ នាទី

## កម្មវិធី

ម៉ោង ១៤.៣០ ចាប់ផ្តើម នមស្សការ (នមោ បទសរភញ្ញ)
បន្ទាប់មកអញ្ជើញវាគ្មិនធ្វើអន្តរាគមន៍ ព្យូរហែ
តាមលំដាប់រហូតដល់ចប់ ។

ម៉ោង ១៦.០០ សម្រាក ១០ នាទី ។

ម៉ោង ១៦.១០ នាទីសំណួរ និង បំភ្លឺ (កុំនិយាយចាកប្រធាន)
អ្នកសួរ ២ នាទី អ្នកបំភ្លឺ ៥ នាទី យ៉ាងច្រើន ។

ម៉ោង ១៦.៥០ ស្រស់ស្រូបនំចំណី ជាកិច្ចបញ្ចប់ ។

កំណត់សំគាល់ : លោក អ្នក ជ្រះថ្លា អាចអញ្ជើញចូលរួមបាន ដោយមេត្រីភាព ។

សូមអរគុណ

**ភិក្ខុ ចិន គេន**

នមត្ថុ រតនត្តយស្ស

ខ្មែរមានពូជ

នៅក្រុង សង់សៀរម៉ាន វត្តពោធិវង្ស ២៦ មេសា ២០០៩
ខ្ញុំព្រះករុណា ខ្ញុំបាទ ឈ្មោះ ស៊ុយ ស៊ាងហេង
កើតនៅឆ្នាំ ១៩៣៦ ខេត្តក្រចេះ កម្ពុជា

សូមក្រាបថ្វាយបង្គំដល់

ទី១-គុណព្រះរតនត្រៃ គឺ គុណព្រះពុទ្ធ គុណព្រះធម៌ គុណព្រះសង្ឃ

ទី២-គុណបុព្វការី ទាំងជិតទាំងឆ្ងាយ ដែលបានជួយស្នួយឲ្យរូប ខ្ញុំបាទ មានជីវិត និង មានចំណេះចេះដឹងខ្លះៗ គ្រាន់ដោះស្រាយបញ្ហាជីវិតជារៀងរហូតមក...... ដោយគោរព ។

ទី៣-សូមស្វាគមន៍ ដល់អង្គប្រជុំជាទីគោរព និង រាប់អាន ដែលឆ្លៀតឱកាសនិមន្ត និង អញ្ជើញមកក្នុងពេលនេះ ដើម្បីនឹងប្តូរយោបល់គ្នាលើប្រធានបទ“ខ្មែរមានពូជ” នេះ ដោយចិត្តស្មោះសរ ។

**សំណូមពរ** ៖

ដើម្បីឲ្យបានជ្រួតជ្រាបសេចក្តីសព្វអន្លើក្នុងប្រធានបទ និង បានសំចៃពេលវេលាផង សូមអង្គប្រជុំមេត្តា ៖

ក-ផ្ទៀងស្តាប់ ចាប់ចុងដើមសេចក្តីឲ្យបាន សេចក្តីណាដែលមិនយល់ច្បាស់ មេត្តាកុំអាលសួរភ្លាម តែសូមកត់លើក្រដាសទុកចាំសួរនៅពេលចោទ-ឆ្លើយ ។

ខ-ចោទសួរ ក្នុងសតិចង់សំចៃពេលវេលា ហើយសូមអង្គប្រជុំមេត្តាដាក់តែសំណួរនៅជុំវិញប្រធានបទ កុំឲ្យចាកប្រធានឲ្យសោះ ។

# ខ្មែរមានពូជ

ពាក្យថា ពូជ គឺតំណជាតិកំណើត ឬ វង្សត្រកូលរបស់ពួកមនុស្ស សត្វ ឬ រុក្ខជាតិ ។ ដូចនេះ មនុស្ស សត្វ រុក្ខជាតិ តែកើតមកហើយ ត្រូវមានពូជទាំងអស់ ។ តែខ្មែរមានទម្លាប់ប្រើថា មនុស្សមានពូជ គឺ មនុស្សមានការអប់រំល្អ ។ លក្ខណៈខ្លះៗដែលល្អ ហើយដែលគួររាប់ថា ជារបស់ខ្មែរយើងពិតៗ មាន ២ ពួក ៖

**ក-លក្ខណៈនៅក្នុងខ្លួន** និង **ខ-លក្ខណៈនៅក្រៅខ្លួន** ។

## ក-លក្ខណៈនៅក្នុងខ្លួន ដែលមានពីកំណើតមក

តាមវិទ្យាសាស្ត្រ មនុស្សលើផែនដីទាំងអស់ មានពូជតែមួយទេ ។ អ្នកប្រាជ្ញខាងវត្ថុបុរាណបានរកឃើញថា កាលពី ៤០.០០០[១] ឆ្នាំមុន មាន មនុស្សដែលប្រកបដោយចរិត លក្ខណៈ ដូចយើងសព្វថ្ងៃ ១ ក្រុម បាន រួចផុតពីស្លាប់រង្គាល នៅក្នុងទ្វីបអាហ្វ្រិក ក្នុងប្រទេសបុតស្វាណា ណាមីប៊ី

---

[១]-៤០.០០០ ឆ្នាំមុន បន្ទាប់ពីមហាភ្នំភ្លើងនៅប៊ិកនេអ្វ (ឥណ្ឌូនេស៊ី) ភ្លើងឆេះ ផែនដី ផ្សែងបាំងព្រះអាទិត្យ ជីវិតនៅលើដី ស្លាប់ស្ទើរតែទាំងអស់ ។ ដំបូងដោយភ្លើង ឆេះគ្មានសល់អ្វី សមុទ្ររីង បន្ទាប់មកដោយគ្មានពន្លឺថ្ងៃ អាកាសត្រជាក់ ។ ក្នុងលោក ទាំងមូល ពូជមនុស្ស ១ ក្រុម មិនដល់ ១.០០០ នាក់ទេ ដែលរួចជីវិតពីមហន្តរាយនេះ គឺ ជនដែលនៅឆ្ងាយពីភ្នំភ្លើង ក្នុងទ្វីបអាហ្វ្រិក ។ ពូជផ្សេងៗទៀត ស្លាប់គ្មានសល់ ។ គេ សន្និដ្ឋានថា សត្វដែលមានសណ្ឋានជាមនុស្ស មានសតិអារម្មណ៍ស្រដៀងមនុស្ស តាំងតែពី ១៩០.០០០ ឆ្នាំមកម្ល៉េះ ។ មានពូជជាច្រើន ។

និង អាហ្វ្រិកខាងត្បូង ។ ពួកមនុស្សដើមនេះ បែកកូនបែកចៅ ក៏សាយភាយពេញពិភពលោក រហូតដល់សព្វថ្ងៃនេះ ។ ដោយឡែក អ្នកប្រាជ្ញខាងលោហិតវិជ្ជា បានសង្កេតឃើញថា ពពួកមនុស្សទាំងនោះ បន្ទាប់ពីបានឆ្លងកាត់ទ្វីប កាត់មហាសាគរមក អ្នកខ្លះក៏រស់នៅក្នុងតំបន់ផ្សេងៗ ។ ក្នុងតំបន់នីមួយៗ មនុស្សមានការប្រែប្រួល ៖ មានធំ ធាត់ ស្គម សស្លាំង ខ្មៅ សម្បុរសណ្តែកបាយ តែរបទាសម្ព័ន្ធឈាម គេនៅតែដដែល គ្មានដូរទេ ។ តែក្រោយមក ចរិត លក្ខណៈ ឈាមក្នុងក្រុមមនុស្សខ្លះ មានដុះខ្នែងប្លែកបន្តិច ឯកូនចៅ សុទ្ធតែទទួលលក្ខណៈឈាម ជាមរតកពីមាតា បិតា ដូនតា រហូតមកមិនដាច់ ។ នេះ សឲ្យឃើញថា ពូជមនុស្ស មានតែមួយគត់ ។

## លោហិតវិជ្ជា វប្បធម៌ និង ជាតិសាសន៍

លោហិតវិជ្ជា[២]និង វប្បធម៌ មានការទាក់ទងគ្នា គេចាប់ទទួលស្គាល់រឿងនេះ តាំងតែពីពេលដែលគេផ្តើមស្រាវជ្រាវរកជំពូកឈាម តាមភូមិសាស្ត្រជាលើកដំបូង ។ ដោយហេតុនេះ ទើបពួកលោហិតសាស្ត្រ បានរកឃើញជាតិ ហេមោគ្លោប៊ីន-អ៊ី Hémoglobine-E (Hb-E) នៅអាស៊ីអាគ្នេយ៍ ក្នុងឈាម នៃ ជនជាតិខ្មែរ ។ រីឯអ្នកប្រាជ្ញខាងបុរាណវត្ថុវិញ ក៏បានរកឃើញគំនរថ្មនៃប្រាសាទបាក់បែក និង ប្រាសាទជំនាន់អង្គរ នៅលើភូមិភាគដដែលនេះដែរ ។ គឺថាបើមានប្រាសាទជំនាន់អង្គរនៅត្រង់ណា

---

[២]- លោហិតវិជ្ជា= ការសិក្សាខាងឈាម ។

គេក៏ឃើញមានជាតិ ហេមោគ្លោប៊ីន-អ៊ី (Hb-E) នៅត្រង់នោះដែរ, គឺនៅក្នុងព្រំដែននៃមហានគរខ្មែរ នាសតវត្សទី ១១[៣] នោះឯង ។

**តើ ហេមោគ្លោប៊ីន ជាអ្វី ?** គឺ ជាជាតិពណ៌ក្រហម នៅក្នុងគុលិកាឈាមក្រហម។ **ហេមោគ្លោប៊ីន** ជាថង់ដាក់អុកស៊ីសែ្សន Oxygéne ជញ្ជូនទៅចិញ្ចឹមកោសិកា នៅសព្វសារពាង្គកាយ (ឈាមពណ៌ក្រហម-ស្រស់) ។ លុះពេលត្រឡប់មកសួតវិញ **ហេមោគ្លោប៊ីន** នេះក៏ស្រូបយកឧស្ម័នកាបូនិច ($Co^2$) ដែលជាកាកសំណល់នៃកោសិកា ត្រឡប់មកចោលក្នុងសួតវិញ (ឈាមពណ៌ក្រហមក្រម៉ៅ) សំណល់នេះនឹងចាកចេញទៅក្រៅខ្លួនយើង នៅគ្រប់ដង្ហើម ។

## ហេមោគ្លោប៊ីន អ៊ី Hb - E ?

គឺជា **ហេមោគ្លោប៊ីន** មិនធម្មតា(ដុះខ្នែងថ្មី) **ហេមោគ្លោប៊ីន** មិនធម្មតាជាច្រើនបានកើតឡើងពីដំណើរប្រែប្រួល[៤] យ៉ាងរហ័សនៃរចនា-

---

(៣)-នេះជាសេចក្តីសន្និដ្ឋានរបស់លោកសាស្ត្រាចារ្យ ស្លង់ បាកណា Pr. Jean BERNARD (1907 - 2009) ។

(៤)-តាមភាពប្រែប្រួល - ដោយប្រការផ្សេងៗ មានធាតុអាកាស, ចំណីអាហារ, ព្យាធិ, រដូវ, សកម្មភាព, ។ល។ ជីវិត (មនុស្ស សត្វ, រុក្ខជាតិ និង វត្ថុ) ក្នុងលោក នេះ សុទ្ធតែវិវឌ្ឍន៍ទៅដោយការប្រែប្រួលជានិច្ច មានខ្លះប្រែប្រួលតាមទម្លាប់ធម្មតា ឯខ្លះទៀត(ភាគតិច) ខុសពីធម្មតា ដូចករណី ហេមោគ្លោប៊ីន-អ៊ី នេះឯង ។ នេះក៏ជាច្បាប់ ធម្មជាតិដែរ ។ ច្បាប់នេះ មិនអនុញ្ញាតនរណា ឬ ក្រុមណាឲ្យនៅបានដោយមិនបាច់ផ្លាស់ប្តូរ (ទីកន្លែង ចិត្តគំនិត រាងកាយ) នោះទេ អ្នកដែលមិនគោរពច្បាប់នេះ ទោះដោយទម្រន់ក្តី ភ្លេចភ្លាំងក្តី ត្រូវតែវិនាសមុនគេជានិច្ច ដោយជម្ងឺក្រិន (រាងកាយ ឬ គំនិត) ។

សម្ព័ន្ធ នៅក្នុងកោសិកាឈាមក្រហម ។ ក្នុងចំណោមមនុស្សដែល **ហេម៉ូគ្លោប៊ីន** ប្រែប្រួលយ៉ាងនេះ លទ្ធផលដែលហុចឲ្យគឺ **ហេម៉ូ-គ្លោប៊ីន** ខ្លះនាំជម្ងឺមកឲ្យគុលិកាឈាមក្រហម អាយុខ្លី។ តែ **ហេម៉ូ-គ្លោប៊ីន** ខ្លះទៀត មិនរុកគួនសុខភាព មនុស្សទេមាន **ហេម៉ូគ្លោប៊ីន-អ៊ី** (Hb-E) ជាអាទិ៍ ជនទាំងនេះអាចរស់ដូចគេឯងជាធម្មតា ។ **ហេម៉ូ-គ្លោប៊ីន**មិនធម្មតាផ្សេងៗទៀត គឺមាន **ហេម៉ូគ្លោប៊ីន** C.D.E.S.។ **ហេម៉ូគ្លោប៊ីន-អ៊ី** (Hb-E) ចាប់មានក្នុងឈាមប្រជាជនខ្មែរ នាសតវត្សទី ១០ និង ទី ១៣ គ.ស. ពេលដែលមហារដ្ឋកម្ពុជាកំពុងរីកធំពេញទំហឹង (*ដែនដីនោះ លាតសន្ធឹងនៅលើ វាលទំនាប និង ដែនដីសណ្ត នៃ ទន្លេមេគង្គ ប្រទេសលាវ ប្រទេសសៀម ភាគខ្លះ នៃ ប្រទេសម៉ាឡេស៊ី និង វៀតណាម សព្វថ្ងៃនេះ*) ។ នៅតំបន់ទាំងនោះគេឃើញមាន បូជនីយ-ស្ថាន[៥] ជាច្រើន ជាអាទិ៍ គឺនៅតំបន់អង្គរ និង ក្រៅព្រំដែន នៃ ប្រទេសខ្មែរសព្វថ្ងៃនេះ ។ ផែនទីនៃភូមិសាស្ត្រ **ហេម៉ូគ្លោប៊ីន-អ៊ី** និងភូមិសាស្ត្រនៃបូជនីយស្ថាន សិល្បៈខ្មែរ ស្មើរតែដូចគ្នាបេះបិទ គឺថា គេអាចយកផែនទីទាំង ២ មកដាក់តម្រួតគ្នាបាន ។ ហេតុនេះហើយ ទើបគេហ៊ានអះអាងថា វាមានការស្របគ្នាយ៉ាងប្រាកដ រវាងបុរាណវត្ថុ និង លោហិតវិជ្ជា ។

នៅប្រទេស ម៉ាដាហ្គាស្ការ (Madagascar) និងនៅប្រទេស អាហ្វ្រិក

---

[៥]- បូជនីយស្ថាន = កន្លែងដែលគួរគោរពបូជា ដូចជាប្រាសាទបុរាណ ព្រះវិហារ សំណង់ផ្សេងៗ ។

ខាងត្បូង (Afrique du Sud) ក៏មាន **ម៉ោម៉ោគ្លោប៊ីន-អ៊ី** ដែរ នេះមកពីនៅសតវត្សទី ១០ អ្នកដើរសំពៅខ្មែរ បានទៅប្រកបមុខរបរ រហូតដល់ប្រទេសទាំងនោះៗ ។

## ជនដែលមាន **ម៉ោម៉ោគ្លោប៊ីន-អ៊ី** ជាមនុស្សបែបណា ?

-អ្នកមាន **ម៉ោម៉ោគ្លោប៊ីន-អ៊ី** មិនមែនជាមនុស្សមានជម្ងឺទេ ។

-**ម៉ោម៉ោគ្លោប៊ីន-អ៊ី** មិនធ្វើឲ្យខូចសុខភាពខាងផ្លូវកាយ ឬ ខាងសតិអារម្មណ៍ទេ ។

-អ្នកមាន **ម៉ោម៉ោគ្លោប៊ីន-អ៊ី** មិនបាច់ត្រូវការកិច្ចព្យាបាលដោយឱសថទេ ។

-គ្មានភ័ស្តុតាងណាមួយបញ្ជាក់ថា **ម៉ោម៉ោគ្លោប៊ីន-អ៊ី** ជាសញ្ញា នៃបុគ្គលប្រសើរជាងគេទេ ។

គុណភាពនៃ **ម៉ោម៉ោគ្លោប៊ីន-អ៊ី** មិនទាន់មានឃើញសរសេរនៅក្នុងអក្សរសិល្ប៍ ខាងវិជ្ជាពេទ្យនៅឡើយទេ នេះជាឱកាសបើកឲ្យអ្នកស្រាវ-ជ្រាវវិទ្យាសាស្ត្រ នឹកគិតក្នុងវិស័យនេះ ទៅថ្ងៃមុខ ។

លក្ខណៈតែមួយដែលគួរឲ្យចងចាំគឺ **ម៉ោម៉ោគ្លោប៊ីន-អ៊ី** ជាសញ្ញាឈាមរបស់មនុស្ស ដែលមានតំណពូជពីខ្មែរជំនាន់អង្គរមក ។ តែមិនមែនមានន័យថាទាល់តែមានលក្ខណៈនេះ ទើបអាចរាប់ថាជាជនជាតិខ្មែរបានទេ ។ មិនដូចនោះទេ ។ **ម៉ោម៉ោគ្លោប៊ីន-អ៊ី** ជាមរតកខ្មែរ ចែកពីមាតា បិតា ដល់កូនចៅតៗគ្នារហូត ។

អាយុជាមធ្យម[៦] នៃជនអ្នកមាន ហេមោគ្លោបីន-អ៊ី ក៏មិនខុសពីមនុស្សដទៃដែរ ។

## ខ-លក្ខណៈនៅក្រៅខ្លួន ដែលខ្មែរបានសន្សំទុកមក

លក្ខណៈនៃ **"ខ្មែរមានពូជ"** ។ ខ្មែរដែលប្រកបដោយចរិយាល្អដោយវិចារណញ្ញាណ គួរតែគិតដល់តម្លៃនៃសម្បត្តិដែលជា បេតិកភ័ណ្ឌ[៧] ជាតិ របស់ខ្លួនជាខ្មែរ គឺមាន ៖

**១-សម័យអង្គរ** = ៤០៨ ឆ្នាំ[៨] (៩៧+២១៤+៩៧) អង្គរវត្ត មិនមែនសង់តែក្នុងរយៈ១ថ្ងៃទេ ។ មានសិលាចារឹកជាភ័ស្តុតាងស្រាប់ ។

-គ.ស. ៨០២ ព្រះបាទជ័យវរ្ម័នទី ២ (ព្រះកេតុមាលា) បង្កបង្កើតឡើងដោយព្រះអង្គបានសិក្សាភូមិសាស្ត្រ នៃតំបន់នោះ ។

-គ.ស. ៨៩៩ ព្រះបាទយសោវរ្ម័ន ទី ១ (កកើតក្រុងអង្គរ)ពី គ.ស.៨០២-៨៩៩= ៩៧ ឆ្នាំ ។

-គ.ស. ១១១៣ ព្រះបាទសុរិយាវរ្ម័ន ទី ២ និងស្តេចឯទៀត(សង់អង្គរវត្ត) ពី គ.ស. ៨៩៩-១១១៣ = ២១៤ ឆ្នាំ ។

---

[៦]-អាយុជាមធ្យម = អាយុជាមធ្យម ដែលសង្ឃឹមថានឹងអាចរស់ដល់ ។

[៧]-បេតិកភ័ណ្ឌ = ទ្រព្យសម្បត្តិ ឬកេរមរតក ដែលមានជាប់មកពីខាងឪពុក (ពីដូនតាមក) ។ [៨]-មហាក្សត្រខ្មែរ ក្នុងជំនាន់អង្គរ (មានស្តេចជាង៣០អង្គ) មានតែស្តេច ១០អង្គទេ ដែលមានមហិទ្ធិឫទ្ធិល្បីខ្លាំងជាងគេ ៕

-គ.ស. ១២១០ ព្រះបាទជ័យវរ្ម័ន ទី ៧ (អង្គរធំ) ពី គ.ស. ១១១៣-១២១០ = ៩៧ ឆ្នាំ ។

ដើម្បីសង់អង្គរ ដូនតាយើងបានធ្វើពិធីបន់ស្រន់អាទិទេព ក៏ពិតមែនហើយ (ក្នុងសង្គមមនុស្សជំនាន់នោះ កិច្ចបន់ស្រន់ នាំឲ្យកើតជំនឿ ចិត្តស្ម័គ្រ និងសាមគ្គីភាព គឺ កម្លាំង) តែមិនមែនអាទិទេពទេ ដែលមកជួយលោកអ្នកដ៏មានគុណរបស់យើង ។ គឺច្បាស់ជាផលនៃកម្លាំងជុំ និង គម្រិះប្រាជ្ញារបស់លោកទាំងនោះ ទើបបូជនីយស្ថានទាំងនោះកើតឡើងបាន ។

រឿងនិទានខ្លះណាដែលមិនគួរជឿ យើងកុំចេះតែយកមកនិយាយ ឬសរសេរតាមតែគេថា ដោយឥតប្រើវិចារណញ្ញាណ ។ កុំយកអាវុធរបស់គេ មកវាយប្រហារពូជពង្សឯង ។ មែនពិត ការនិទានរឿងព្រេងត្រូវតែមាន ព្រោះជាការបណ្ដុះគំនិតដល់យុវជន ក៏ ប៉ុន្តែ កុំភ្លេច បញ្ជាក់ពីហេតុបច្ច័យផង ពុំនោះសោត និយាយរឿងមិនពិត មានផលវិបាកអាក្រក់ជាច្រើនដល់កេរ្តិ៍ឈ្មោះយើង។ នេះមិនមែនជាអំពើនៃអ្នកស្រឡាញ់ជាតិទេ ។ ដូចជាក្នុងរឿងសង់ប្រាសាទអង្គរវត្ត មាននិទាន ជាច្រើនដែលមួយៗសុទ្ធតែអះអាងថា អ្នកនេះ អ្នកនោះ ដែលមិនមែនខ្មែរជាអ្នកសាងសង់ ៖

-ព្រះកេតុមាលា ជាកូនកាត់ មនុស្សលោក និង ព្រះឥន្ទ្រ,

-កូនតាលីម-សេង ជាតិចិន មកពីស៊ាងហៃ, សង់អង្គរវត្តតែក្នុងរយៈ១ថ្ងៃ ។

-ព្រះវិស្ណុការ ទេវតា ជាជាងរបស់ព្រះឥន្ទ្រ យកដីឥដ្ឋមកសូនជា

អង្គរវត្ត រួចហើយក៏សូត្ររបៀន ឲ្យប្រែជាថ្ម ។

គេមិនដែលនិយាយសោះ ពីបច្ចេកទេសដឹកជញ្ជូនថ្ម ឆ្លាក់ថ្មលើកតម្រៀប ជាក្បាច់ក្បូរ ។ល។ ដែលជាកម្លាំង និង ប្រាជ្ញាខ្មែរសុទ្ធៗ ។ គឺគេមាននិយាយតែពីបរទេសមកធ្វើប្រាសាទឲ្យខ្មែរ ជាអ្នកមានបុណ្យទៅវិញ គេមិនបានបង្ហាញកូនខ្មែរ ឲ្យស្គាល់តម្លៃខ្លួនឯង គឺជម្រុញឲ្យឆ្គាភ្លេច ឲ្យស្អប់ពូជពង្សខ្មែរ តែម្តង ។

**២-គោគសម្បត្តិ** ភាសិតបារាំង "*ប្រាក់ជាអ្នកបំរើដ៏ល្អ តែជាចៅហ្វាយដ៏អាក្រក់*" ។ គតិធម៌នេះ ជូនតាយើងបានស្គាល់ច្បាស់ណាស់ ។ បើមានទ្រព្យហើយ លោកដើរចៅឡៃនោះ លោកច្បាស់ជាគ្មានប្រាសាទស្កឹមស្កៃទុកជាកេរមកដល់យើងសព្វថ្ងៃទេ ។ សូមជួយសង្កេតមើល ។ នៅ គ.ស. ៨០២ ព្រះបាទជ័យវ្ម័ន ទី ២ មកតាំងរាជធានីនៅភ្នំគូលែន ព្រោះជាទីកន្លែងដ៏ប្រសើរ មានប្រភពនៃស្ទឹងទាំងឡាយ (ស្ទឹងពួក ស្ទឹងសៀមរាប ស្ទឹងរលួស) ដែលហូរកាត់ដីទំនាបខេត្តសៀមរាប ចុះទៅបឹងទន្លេសាប ។ ការរើសយកទីនោះ គឺមិនមែនដោយចៃដន្យទេ គឺពិតជាព្រះអង្គទ្រង់ឈ្វេងយល់ថា ជាកន្លែងមានសក្តានុពល អាចបង្កបង្កើនផលបាន គឺ មានដីវាលធំ(ស្រែ) និង មានបឹងទន្លេសាប (ត្រី) នៅជិត ដែលជា ប្រភពនៃ ⇨

| | | | |
|---|---|---|---|
| ម្ហូបអាហារបរិបូរណ៍ ⇨ | ធនធានមនុស្ស ⇨ | អភិវឌ្ឍន៍សេដ្ឋកិច្ច ⇨ | ជីវភាពរីកចំរើនឆាប់ ⇨ |
| បច្ចេកទេស ⇨ | និងសិល្បៈដុះដាល | ។ល។ | |

(ពោះដែលឃ្លាន គ្មានត្រចៀកទេ) ។

## ៣-វប្បធម៌

**អក្សរសាស្ត្រ**-ក្នុងចំណោម ១៩២ ប្រទេស ដែលជាសមាជិកអង្គការសហប្រជាជាតិ សព្វថ្ងៃនេះ មានអក្សរសាស្ត្រតែចំនួន ២៦ ភាសាទេ ដែលក្នុងចំណោមនោះ មានខ្មែរយើងមួយដែរ ។ នេះ គឺជាកេរពីដូនតាមួយ ដែលគួរយើងខ្មែរនាំគ្នាភ្ញាក់ស្មារតី ជួយជ្រោមជ្រែងថែរក្សាទុកដោយមោទនភាព ។ ច្បាប់ក្បួនសន្លឹក ដែលប្រទេសខ្លះ ដកស្រង់ទៅផ្សែផ្សំជាមួយនឹងវិជ្ជាទំនើប ហើយប្រតិបត្តិតាមបានលទ្ធផលដ៏ប្រសើរ ។

លោកតា កេង វ៉ាន់សាក់ សង្កេតឃើញថា ភាសាខ្មែរ មានខ្យល់ក្នុងព្យាង្គ ដែលឲ្យន័យតាមពួកដូចជា ៖

ពួកខ្យល់ "**អាប**" ន័យថា មិនមែនខ្ពស់= បាប, ទាប, រាប, ដាប, ក្រាប, ស្រប៉ាប, សាប,

ពួកខ្យល់ "**អះ**" ន័យថា កម្លាំង= ឈ្នះ, ត្រះ, ព្រះ, រះ, ជ្រះ, ទះ, ផ្ទះ, យះ, រន្ទះ, រលះ, លះ, វះ, លោកបានបញ្ជាក់ទៀតថា នេះគ្រាន់តែជាសញ្ញាតូចមួយបង្ហាញឲ្យយើងយល់ថា បេតិកភ័ណ្ឌជាតិយើងមានឥទ្ធិពលជាច្រើន ដែលកប់ខាងក្នុងអក្សរសិល្ប៍ក្តី ភាសាក្តី ទំនៀមទម្លាប់ក្តី ហេតុនេះ គួរតែខ្មែរខិតខំស្រាវជ្រាវរកយកមកប្រើការ ។ ត្រូវតែ យើងមានសង្ឃឹមឡើងវិញ ។

**សិល្បៈ** - តន្ត្រី និង ចម្រៀង-ល្ខោន-អាយ៉ៃ-កាព្យឃ្លោង(កវី-និពន្ធ) ចម្លាក់-គម្ពាញ ។ល។

**របៀបរស់នៅ** - ក្បួនធ្វើម្ហូបអាហារ-បរិក្ខារ-ក្បួនខាងសំណង់-ខាងសុខភាពអនាម័យ , អាពាហ៍ពិពាហ៍ (**បង្វិលពពិល**)[៨] ៖

អ្នកបង្វិល, ភ្លើងទៀន ៣, ជយន្តោ ។ល។

**៤-សក្តានុពល**[៩] **ខ្មែរម្នាក់ៗ** Potentiel

ខ្មែរជាច្រើន មានគ្រាប់ពូជនេះក្នុងខ្លួនស្រាប់ គឺជាទេពកោសល្យ[១០] នៃការប៉ិនប្រសប់ណាមួយ ខ្លះខាងនេះ ខ្លះខាងនោះ : ចម្លាក់, សំណង់,

---

[៨]- បង្វិលពពិល= គឺជាប្រស្នា, ការពន្យល់ដោយឲ្យយើងយកមកគិត ។ នេះជារបៀបប្រដៅកូនចៅក្រោយឲ្យចេះសង្កេតមើល, ឲ្យចេះចាំដើម្បីរក្សាមង្គលក្នុងគ្រួសារ ន័យគឺ ៖ 1-អ្នកអង្គុយបង្វិលពពិល សុទ្ធតែគូជាប្តីប្រពន្ធដែលសន្មតថា បានរៀបការត្រឹមត្រូវឪពុកម្តាយ មិនអាចចូលក្នុងក្រុមនេះបានទេ ពីព្រោះក្រុមនេះតំណាងសង្គមដែលគូស្វាមីភរិយាថ្មី ត្រូវទទួលខុសត្រូវចំពោះមុខសង្គម ចាប់ពីពេលនេះតទៅ ។ 2-ភ្លើងទៀន៣ តំណាងភ្នក់ភ្លើងទាំង៣ ក-គ្រួសារថ្មីនេះ ខ-គ្រួសារជាដន្លងទាំងពីរខាង ។ ចាស់ទុំលោកប្រាប់ថា អ្នកទាំងអស់គឺស្វាមីភរិយាថ្មី ដន្លងខាងប្រុស និង ដន្លងខាងស្រី ត្រូវរក្សាភ្លើងទាំង៣ភ្នក់នេះ កុំឲ្យរាលដាលឆេះផ្ទះ គឺកុំនាំភ្លើងចុះឡើង ។ 3-ធម៌ ជយន្តោ... ដែលអាចារ្យសូត្រ មានន័យថា ៖ សិរីសួស្តី, ជ័យមង្គល ឬ នក្ខត្តឫក្សល្អ សុទ្ធតែកើតឡើងដោយអំពើ កាយល្អ វាចាល្អ ចិត្តល្អ ទាំងអស់ ។ ករណីណា ដែលអ្នកបានធ្វើអំពើល្អអ្នកនឹងទទួលសិរីសួស្តី ជ័យមង្គល នក្ខត្តឫក្សល្អជានិច្ច (ដូចនេះ ក្នុងធម៌ **ជយន្តោ...** គ្មានឃើញត្រង់ណាដែលប្រាប់ថា ត្រូវបន់ស្រន់សោះ) ។ [៩]-សក្តានុពល= កម្លាំងគ្រប់អន្លើដែលអាចយកផលបាន ។ កម្លាំងនេះនឹងអាចបញ្ចេញឲ្យផលបានលុះណាតែត្រូវទេសៈកាលៈ ព្រោះជួនកាលអ្នកមានកម្លាំងនេះ មិនទាំងដឹងថា ខ្លួនមានកម្លាំងបែបនេះផង ។ [១០]-ទេពកោសល្យ= ការប៉ិន ប្រសប់, ការឈ្លាសវៃពីក្នុងខ្លួន ។

គំនូរ, នព្វន្ត ។ល។ ដូចមាន :

-គំនិតផ្តួចផ្តើមផលិតថ្មីៗ (Initiative ) ជាអាទិ៍

-ចិត្តពុះពារ-ស្ម័គ្រស្មោះ-ពលីកម្ម-អត់ធន់ ។

*សង្កេតមើល ខ្មែរនៅក្នុងស្រុក*

យើងសង្កេតទៅឃើញកូនខ្មែរដែលកើតក្រោយ ១៩៧៥ សុទ្ធតែមិនសូវបានរៀនសូត្រវិជ្ជាអ្វីច្បាស់លាស់ទេ ។ តែអ្នកទាំងនោះ នៅពេលណាគេបានស្គាល់ចំណេះវិជ្ជាខ្លះ ក៏ឆាប់យល់ ឆាប់ធ្វើកើត ហាក់ដូចជាបានជួបនឹងការងារទាំងនោះមកខ្លះហើយ ។

*សង្កេតមើល ខ្មែរនៅក្រៅស្រុក*

ខ្មែរដែលមានចំណេះវិជ្ជាខ្ពង់ខ្ពស់ ក៏មានមិនតិចដែរ ។ នៅសាលាដែលល្បីល្បាញក្នុងលោក មានកូនខ្មែរជាច្រើនបានចូលរៀន ហើយប្រឡងបានសញ្ញាប័ត្រ មានមុខរបរគួរជាទីពេញចិត្ត ។ នៅក្នុងសហគ្រាសធំៗ មានខ្មែរជាច្រើន កាន់ការសំខាន់ៗ បើខ្មែរអន់ ហេតុអ្វី ក៏អាចធ្វើការទាំងនោះកើត ? តើហេតុអ្វីបានជាខ្មែរយ៉ាប់រហូត តាំងពីសតវត្សទី ១៤ មកងើបមុខមិនទាន់រួចសោះ ? តើមកពីថ្នាក់ដឹកនាំ ឬមកពីថ្នាក់តាម ឬក៏ មកពីហេតុផ្សេងទៀត ។

**៥-សម្បត្តិធម្មជាតិ** ដីមានជីជាតិ បឹង ទន្លេ សមុទ្រសម្បូរត្រីព្រៃឈើ អាចផ្តល់ចំណីអាហារ និង បរិក្ខារយ៉ាងបរិបូរ ។

**៦-ព្រះពុទ្ធសាសនា** ចាស់បុរាណខ្មែរបានព្រមានថា

ប្រយ័ត្ន ! ថ្វាយបង្គំព្រះ ប៉ះស៊ីម៉ង់ត៍ ថ្វាយបង្គំព្រះសង្ឃ ប៉ះកូនអ្នកស្រុក ។

បើលោក អ្នក ទៅវត្ត ហើយបែរទៅថ្វាយបង្គំស៊ីម៉ង់ត៍ទៅវិញ តើកំហុសនេះធ្លាក់ទៅលើអ្នកណា ? ធ្លាក់លើលោកសិស្ស ឬ ធ្លាក់លើលោកគ្រូ ? សូមមេត្តាសាកពិចារណាមើលផងចុះ ។ ក្នុងព្រះពុទ្ធដីកា (តារាងខាងក្រោមនេះ) យើងមិនឃើញពិធីសូត្រលើករាសី ចងខ្សែ ចំរើនអាយុ ស្រោចទឹក ។ល។ ឯណាសោះ ។ ហេតុដូចម្តេច ក៏មាន ពិធីនេះ ? មួយវិញទៀត ពុទ្ធមាមកៈទាំងអស់ ធ្លាប់សូត្រយ៉ាងរត់មាត់ថា នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ...(១០) មិនដែលខានទេ ។ តើសូត្រឲ្យអ្នកណាស្តាប់ ? អ្នកដែលបានចូលមកជិត ដើម្បីរកមើលកិច្ចបដិបត្តិ ខាងព្រះពុទ្ធសាសនា តើគេនឹងយល់យ៉ាងណាទៅ បើគេឮខុសពីឃើញរបៀបនេះ ? តើការប្រតិបត្តិបែបនេះ នឹងហុចផលយ៉ាងណាដល់សង្គម និងសាសនាយើង ដែលជាកត្តាមួយ អាចជួយជ្រោមជ្រែងបានមួយភាគធំដល់សក្តានុពល កូនខ្មែរ **"ខ្មែរមានពូជ"** ទៅអនាគត ? យើងគួរនាំគ្នាសិក្សា ដើម្បីប្រតិបត្តិសាសនាយើងឲ្យបានត្រឹមត្រូវ ហ្មត់ចត់ តាមព្រះធម្មវិន័យ ដែលយើងកោតសរសើរមិនដាច់ពីមាត់ ។

---

(១០)- ពុទ្ធមាមកៈ= អ្នកកាន់ពុទ្ធសាសនា ធ្លាប់សូត្រ នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ មេ សរណំ វរំ ដែលប្រែថា វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណា មិនមានឡើយ មានតែព្រះពុទ្ធជាម្ចាស់ ជាទីពឹងទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា ។

## ព្រះសិទ្ធត្ថគោតម[១១] ជាគ្រូដើម នៃ យើងបានទូន្មានថា ៖

| | | |
|---|---|---|
| ១-វៀរចាកអំពើអកុសល(បាប) | ២-សន្សំកុសល(បុណ្យ) | ៣-ជុះខាត់ចិត្តខ្លួនឲ្យផូរផង់ |
| សីល ៖ សីល៥ ឬ និច្ចសីល[១២] | សមាធិ ៖ សមថកម្មដ្ឋាន | បញ្ញា ៖ វិបស្សនាកម្មដ្ឋាន |
| សម្មាវាចា= សំដីត្រូវ | សម្មាវាយាមះ= ព្យាយាមត្រូវ | សម្មាទិដ្ឋិ= យល់ឃើញត្រូវ |
| សម្មាកម្មន្តះ= អំពើដោយកាយត្រូវ | សម្មាសតិ=ស្មារតីត្រូវ ការរឭកត្រូវ | សម្មាសង្កប្បះ= ត្រិះរិះត្រូវ |
| សម្មាអាជីវះ= ចិញ្ចឹមជីវិតត្រូវ | សម្មាសមាធិ= ចិត្តមូលត្រូវ | |
| ព្រះពុទ្ធ បានបញ្ជាក់គាថានេះថា៖ ចប់តែត្រឹមនេះ គ្មានត្រូវបន្ថែម ឬ បន្ថយអ្វីចេញទេ ។ | | |

# សេចក្ដីបញ្ចប់

សង្កេតឃើញហេតុផលទាំងនេះហើយ ចិត្តខ្មែរយើង ត្រូវតែរីករាយ ជួយអរសាទរដោយមោទនភាព[១៣] និងក្ដីសង្ឃឹម, ខ្មែរគ្រប់វ័យ គួរខំប្រឹងខ្លួនឯងផង និងឈឺឆ្អាលដល់បងប្អូនយើងដែលមានសក្ដានុពល តែខ្វះ-

---

[១១]-សិទ្ធត្ថគោតម(សិតធាត់ថះគោដំ),គោតមជានាមត្រកូល ឯ សិទ្ធត្ថ ជានាមខ្លួន។ ពុទ្ធ ជាសាធារណនាម, មានន័យថា អ្នកត្រាស់ដឹងធម៌ពិត គឺអរិយសច្ចះទាំង៤ ជាដើម

[១២]-សីល ៥ ឬ និច្ចសីល= វៀរចាក ១-សម្លាប់សត្វ, ២-យកទ្រព្យអ្នកដទៃដែលគេមិនបានឲ្យដោយកាយ ឬ ដោយវាចា, ៣-ប្រព្រឹត្តខុសក្នុងកាម, ៤-ពោលពាក្យកុហក, ៥-បរិភោគគ្រឿងស្រវឹង គឺសុរានិងមេរ័យ ។ គឺជាចរិយាធម៌ដែលត្រូវជៀសវាងរហូត ។

[១៣]- មោទនភាព ចិត្តត្រេកអរ ជួយរីករាយនិងផលល្អ ។ គឺត្រេកអរសាទរជាមួយគ្នា ។

មធ្យោបាយ គួរយើងជួយឲ្យមានមធ្យោបាយ ដើម្បីជម្រុញសង្គមខ្មែរយើងឲ្យរើបម្រះចេញពីងងឹតទៅរកភ្លឺ គឺឈោងយកកិត្យានុភាព[១៤]ជាតិឲ្យបានមកវិញ ។ ខ្មែរយើងត្រូវរក្សាឧត្តមគតិតែមួយ គឺយើងមានវត្ថុធាតុដើមជាច្រើន ដូចដែលបានរៀបរាប់ខាងលើស្រាប់ ។ វត្ថុទាំងនេះ យើងនឹងនាំគ្នាឆ្នៃឲ្យកើតជាផលិតកម្មយ៉ាងស័ក្តិសិទ្ធិ ។

## ពាក្យចាស់ ពូជ និង គំនិតពុទ្ធសាសនា នៅក្នុងច្បាប់ក្រមង៉ុយ

<u>ទំព័រ ៣០</u>

ពាក្យចាស់លោកថា ធ្វើស្រែចំការ ស្តាប់មហាសង្ក្រាន្ត
ធ្វើម្តងខុសខាត ធ្វើម្តងទៀតបាន ធ្វើតាមប្រមាណ
ប្រមើលទឹកភ្លៀង ។

រកប្តីប្រពន្ធ ឲ្យគយឲ្យគន់ រើសរកប្បរាង
ពូជថ្លៃល្អមយក ពូជថោកល្អមវាង រូបល្អឫកល្អៀង
នាងកុំប្រសព្វ ។

ជាតិស្រីនិងប្រុស បើបានជាខុស ខុសទាល់ចាស់ងាប់
បើបានរូបល្អ កម្រមានភ័ព្វ មានខុសមិនគាប់
ដូច(ដូវ)ស្រែចំការ ។

---

[១៤]- កិត្យានុភាព= កេរ្តិ៍ឈ្មោះល្បីល្បាញ មានគេកោតសរសើរ ។

ទំព័រ ៣៦

កូនចៅស្រីប្រុស ចំណាំទុកចុះ ទុកជាតម្រា
គួរយកតម្រាប់ គួរស្តាប់ពុទ្ធដីកា ព្រះអង្គទេសនា
គាថាបួនបទ ។

រៀនគ្រាប់អ្នកប្រាជ្ញ បើចង់ឈ្នះកាច យកស្លូតសង្កត់
ចង់ឈ្នះមនុស្សខឹង ឱ្យប្រឹងខំអត់ វាជេរវាហត់
វាស្ងួបលែងខឹង ។

ចង់ឈ្នះអសុរោះ ស្តីលេងឡេះឡោះ កុំធ្វើជាដឹង
យើងស្តីត្រង់ណា ឱ្យចំត្រង់ហ្នឹង ឃើញឬកយើងរឹង
ខ្លាចយើងខាងក្រោយ ៕

**ចប់**

# ខ្មែរមានពូជ

(ឬលក្ខណៈ នៃ ជនជាតិខ្មែរ)

ពាក្យថា " ខ្មែរមានពូជ" គឺខ្មែរជាអ្នក បានទទួលកេរមរតក ដំណែលពី ជីដូន ជីតា និង មានអារ្យធម៌ របស់ជាតិសាសន៍ខ្លួនផ្ទាល់។ ក្នុងសម័យបច្ចុប្បន្ននេះ តម្លៃប្រពៃណីរបស់ប្រជាជនខ្មែរ ហាក់ដូចជាមាន តែនៅក្នុង ទីវត្តអារាមប៉ុណ្ណោះ ។ ដោយហេតុថា ព្រះពុទ្ធសាសនា ជាសសរគ្រឹះចម្បងនៃសង្គមជាតិខ្មែរជាច្រើនរយឆ្នាំមកហើយ ។ ប៉ុន្តែ តម្លៃរបស់ប្រជាជនខ្មែរ មិនមែនមានត្រឹមតែវិស័យសាសនា សីលធម៌ និង សង្គមកិច្ចទេ គឺមាននៅក្នុងវិស័យអក្សរសាស្ត្រ បច្ចេកទេស សេដ្ឋកិច្ច និង សិល្បៈផ្សេងៗ ទៀតដែរ ។

បើយើងសិក្សាតាមដំណើរប្រវត្តិសាស្ត្រ គឺចាប់ផ្តើមពីសតវត្សទី១ នៃគ្រិស្ត សករាជ យើងមានឯកសារជាច្រើនបង្ហរ ស្តីពីស្ថានភាពស្រុកខ្មែរ និង ជីវភាពនៃប្រជាជនខ្មែរ។ ក្រោយមកទៀត ឯកសាររបស់ចិន និង ឯកសារដែលគេរក្សាទុកនៅ "សាលាបារាំង នៃ ចុងបូព៌ាប្រទេស" (Ecole Française d'Extrême Orient) បានបញ្ជាក់ថា ប្រជាជនខ្មែរ មានការរីកចំរើនជាលំដាប់ដោយសារ មានការខិតខំប្រឹងប្រែង យ៉ាងស្វាហាប់ ដើម្បីឲ្យការចេះដឹងរបស់ខ្លួន កើតឡើងជាបន្តបន្ទាប់ ដែលជាលក្ខណៈពិសេសថ្លៃថ្នារបស់ជាតិខ្មែរតែម្តង ។

## ១- ការចេះដឹង ដែលបានមកពី ឥណ្ឌា

នៅឆ្នាំ១៩៦០ អ្នកប្រាជ្ញបារាំងឈ្មោះ ហ្សង់ ហ្វីលីយ៉ូស្ហាត៍ (Jean Filliozat) (១) បានធ្វើសន្និសីទស្តីពី វប្បធម៌ខ្មែរ នៅវិជ្ជាស្ថាន គរុកោសល្យ នាទីក្រុងភ្នំពេញ ។ លោកបានពន្យល់ថា នៅក្នុងប្រវត្តិសាស្រ្ត អារ្យធម៌ឥណ្ឌា បានជ្រាបចូលមកប្រទេសកម្ពុជាជាលំដាប់ ។ តាមការពិត ខ្មែរមិនបាន"ធ្វើតាម"ឬ"ចម្លងតាម"វប្បធម៌ឥណ្ឌាគ្រប់វិស័យនោះទេ គឺខ្មែរបាន "ចាប់យក" គំនិតស្មារតីឥណ្ឌា ហើយបាន"បង្កើតជារូបរាងថ្មី" ដើម្បីទុកជាសមិទ្ធិកម្មរបស់ខ្លួនផ្ទាល់ ។ ដូច្នេះហើយ ទើបលោក ហ្សង់ ហ្វីលីយ៉ូ-ស្ហាត៍ បានកត់សំគាល់ថា អក្សរខ្មែរលើកដំបូងបង្អស់ គ្មានជាប់ទាក់ទង ជាមួយនឹងអក្សរឥណ្ឌា ទោះក្នុងរចនាសម្ពន្ធក្តីឬក្នុងការប្រើវាក្យសព្ទសំខាន់ៗក្តី ។ ជាបន្ទាប់មកគឺក្រោយពីវប្បធម៌ឥណ្ឌា បានចូលមកដល់ ទើបគេបានឃើញថា អក្សរខ្មែរ ដែលសរសេរលើសិលាចារឹកជាមុនដំបូងនោះ មានភ្ជាប់ជាមួយនឹងអក្សរនៃភាសាសំស្រ្កឹត (មកពីឥណ្ឌា) ព្រោះអក្សរខ្មែរ ត្រូវបានសរសេរភ្ជាប់នឹង (អក្សរសំស្រ្កឹត) ជាច្រើន ។

ឥណ្ឌា បានផ្សាយទ្រឹស្តីសាសនា និងអារ្យធម៌របស់គេទៅនៅគ្រប់តំបន់រហូតដល់ប្រទេស ទីបេត៍ (Tibet) និងប្រទេសខ្មែរ ។ ប៉ុន្តែ ខ្មែរបានបង្កើតមូលដ្ឋាន និង ទម្រង់ទ្រឹស្តីសាសនាថ្មី ដោយគំនិតផ្ទាល់ខ្លួន

---

(១) L'esprit de la civilisation khmère par M. Jean Filliozat, Professeur au Collège de France, Directeur de l'Ecole Française d'Extrême Orient, in, *Cambodge d'Aujourd'hui*, janvier 1960, Phnom Penh, pp.1-23.

ព្រមទាំងបង្កើតឈ្មោះ ឋានៈ និង តួនាទី នៃអាទិទេព ភាពជា ក្សត្រិយ៍ បព្វជិត ឲ្យមានជាឋានានុក្រមផ្សេងៗ ដែលមានលក្ខណៈ ច្បាស់លាស់ ជាងនៅក្នុងឋានានុក្រមឥណ្ឌា ទៅទៀត ។

ម្យ៉ាងទៀត ក្នុងការសាងសង់ បូជនីយដ្ឋាន ឬ វិហារ ព្រមទាំង រូបចម្លាក់ លោក ហ្សង់ ហ្វីលីយ៉ូស្ហាត៍ បានកត់សំគាល់ថា ខ្មែរបានធ្វើ តាមលំនាំរបស់ ឥណ្ឌាមែន ប៉ុន្តែ ខ្មែរចេះឆ្លាក់ រចនាបញ្ចេញភាព ត្រចះត្រចង់ប្លែកពី ឥណ្ឌាទាំងអស់ ។ យើងមិនដែលឃើញ បូជនីយដ្ឋាន ខ្មែរណាមួយបញ្ជាក់ប្រាប់ថាពីការចម្លងចម្លាក់ផ្ទាល់របស់ឥណ្ឌាទេ ។

លោក ហ្សាក់ ឌុយម៉ាសៃ (Jacques Dumarçay)[២] ដែលសិក្សា អំពី "ប្រាជ្ញារួមគ្នានៃប្រជាជន" បានពន្យល់ថា ការកសាង វិមាន ប្រាសាទ ឬ ក៏ធ្វើរូបចម្លាក់ ក្រុមអ្នកបច្ចេកទេសខ្មែរ បានទៅរកគំរូពីប្រទេស ឥណ្ឌាមែន ។ ប៉ុន្តែ វិមានដែលលោកបានឃើញ គឺមានលំអគ្រប់ទិដ្ឋភាព ដូច ប្រាសាទបក្សីចាំក្រុង ដែលខ្មែរបានកសាងឡើង ក្នុងសតវត្ស ទី ៩ ។ ចាប់តាំងពីសតវត្សទី១០មក ខ្មែរទាំងអស់នោះ ក៏បានក្លាយទៅ ជាគ្រូខ្លួនឯង ពីព្រោះបានយល់ច្បាស់លាស់ ពីបច្ចេកទេសនៃការសាងសង់ ។ ភស្តុតាង គឺប្រាសាទតាកែវ ឬ ប្រាសាទប្រែរូប ដែលខ្មែរបាន កសាងដោយលើកកំពស់ឲ្យខ្ពស់បាន ដោយមិនចាំបាច់ផ្លាស់ប្តូររូបរាងនៃ

---

[២]- Intelligence collective et architecture en Asie du Sud-Est, par Jacques Dumarçay, in, *Annales HSS*, mai-juin 1998, n°3, pp.505-535.

ផែនការសំណង់ទេ ។

ពីសតវត្សទី១០ ទៅសតវត្សទី១២ ប្រទេសខ្មែរមិនបាន ជួបប្រទះពីបញ្ហាសេដ្ឋកិច្ចទេ ព្រោះបច្ចេកទេសនៃសំណង់ទំនប់ទឹក បានឡើងកំរិតយ៉ាងខ្ពស់ មានទឹកប្រើប្រាស់គ្រប់វិស័យធ្វើឲ្យកសិកម្ម ផ្តល់ភោគផលជាអតិបរមា ។ ភោគផលទាំងអស់នេះ ជាអាហារ ដែលជាជំនួយដល់ការសាងសង់វិមាន និង ប្រាសាទនៅព្រះរាជាណាចក្រខ្មែរ ជាច្រើនឥតឈប់ឈរ ។

ចំពោះលោក ហង់រី ម៉ារសាល់ (Henri Marchal)[៣] វិញ គឺការធ្វើរូបចម្លាក់របស់ខ្មែរ និង របស់ឥណ្ឌា មានភាពមិនដូចគ្នាទេ ។ របៀបឆ្លាក់ជារូបសត្វ រូបយក្ស ឬ រូបទេវតា ខ្មែរបានយកតាម ឥណ្ឌាមែន ប៉ុន្តែ គំនិត និង គោលដៅក្នុងការឆ្លាក់រូបទាំងនោះ គឺខុសពីឥណ្ឌាស្រឡះ ។ ចម្លាក់ខ្មែរ ប្លែកពីគំរូចម្លាក់ ឥណ្ឌា ទាំងអស់ ។

## ២- ការរៀបចំប្រទេសខ្មែរ

តាមឯកសារចិន តាំងពី សតវត្សទី៥មក ស្រុកខ្មែរ មានឈ្មោះថា "ហ្វូណន់" ។

---

[៣] -L'indépendance de l'art khmer vis-àvis de l'art indien par Henri Marchal, Consercvateur d'Angkor, in, *Revue des Arts asiatiques*, III° Année , n°4, Décembre 1926, pp.173-179.

យោងតាមឯកសារលោក ប៉ូលប៉ែលីយោ (Paul Pelliot)[៤] ថា មានព្រលឹងមួយបានទៅពន្យល់សប្តិ ប្រាប់ព្រាហ្មណ៍ម្នាក់ឈ្មោះ កោណឌី-ញៈ ថាឲ្យធ្វើដំណើរចូលទៅប្រទេស ហ្វូណាន់ ។ ពេលព្រាហ្មណ៍នោះមកដល់តាមការយល់សប្តិ ប្រជាជននៅ ហ្វូណាន់ បាននាំគ្នាទៅ "ហែហម" ព្រាហ្មណ៍នោះឲ្យមករៀបចំស្រុកខ្លួន។ ស្តេចស្រុក ហ្វូណាន់ ក៏បានចាប់ផ្តើមដាក់ ការទូតជាមួយនឹងប្រទេសចិន ក្នុងឆ្នាំ ៣៥៧ ។ បន្ទាប់មក ស្តេចខ្មែរ បានធ្វើជំនួញជាហូរហែ ជាមួយស្រុកចិន ជាពិសេស នៅខែត្រ កង់តុង ។

នាសម័យនោះ ភូមិសាស្ត្រ[៥] របស់ព្រះរាជាណាចក្រខ្មែរ មានទឹកដីធំទូលំទូលាយណាស់ គឺលាតសន្ធឹងដល់ទឹកដី សព្វថ្ងៃនៃ ប្រទេសឡាវ ខាងក្រោមភូមិភាគជុំវិញទន្លេមេណាមទាំងអស់ ព្រមទាំង ប្រទេសយួនខាងត្បូងទាំងមូល និង ប្រទេសកម្ពុជាបច្ចុប្បន្ននេះ ។ គេ បាននិយាយថា ប្រជាជនខ្មែរ មានចំនួន ១០លាននាក់ នៅក្នុងរជ្ជកាល នៃ ព្រះបាទសុរិយាវរ្ម័នទី២ (ឆ្នាំ១១១៣-១១៤៥) ។

---

[៤]- Le FOU-NAN, par Paul Pelliot, Professeur à l'Ecole française d'Extrême Orient, in , *Bulletin de l'Ecole française d'Extrême Orient,* Tome 3, 1903. pp.248-672.

[៥]- L'Empire Khmer - Histoire et Documents, par Georges MASPERO, Administrateur des Services Civils de l'Indo-Chine, Phnom Penh, Imprimerie du Protectorat, 1904. Voir aussi le long texte d'un savant américain Lawrence Palmer Briggs : « The Khmer Empire and the Malay Peninsula », in, *The Far eastern Quarterly,* vol, 9, N°3, ( May 1950), pp. 256-305.

ការរៀបចំព្រះរាជាណាចក្រ រាជរដ្ឋាភិបាល ត្រូវនៅក្រោមអំណាចនៃក្រុមគ្រួសារអភិជនរបស់ពួកព្រាហ្មណ៍ និង របស់វង្សក្សត្រ ។ សង្គមខ្មែរមានឋានានុក្រមច្បាស់លាស់ណាស់ គឺពួកនាម៉ឺន សព្វមុខមន្ត្រី មេកងទ័ព អស់អ្នករាជការ ទាហានយោធា និង ប្រជាជនទូទៅ ។ ឯជនបរទេសវិញ មាន ឥណ្ឌា ចិន ចាម សៀម។ល។

ចំពោះកងទ័ពខ្មែរ លោក ហ្វ្រង់ វ៉ាំងសង់(Frank Vincent)[៦] បានឲ្យដឹងថា កងទ័ពដំរីមាន ៧០ ០០០ ក្បាល កងទ័ពសេះមាន ២០០ ០០០ ក្បាល កងទាហានថ្មើរជើងមាន ៦០០ ០០០ នាក់ ព្រមទាំងទ្រព្យសម្បត្តិ សម្ភារៈសឹក ជាច្រើនសន្ធឹកទៀត ។ នាពេលនោះទីក្រុងអង្គរ មានភូមិផ្ទះចំនួន ២០ ០០០ មានទីឧទ្យាន សាធារណៈជាច្រើន ដែលតុបតែងដោយគ្រឿងមាស ពេជ្រ កែវចរណៃ និង ភ្លុកដំរី ។ គេឃើញមានទីក្រុងធំៗ ចំនួន៣០ ហើយទីក្រុងនីមួយៗ មានភូមិ ផ្ទះចំនួន ១ ០០០ ជាមធ្យម ។ ប្រទេស កម្ពុជា នាសម័យនោះ ជាប្រទេសសម្បូរសប្បាយជាងគេបំផុត នៅក្នុងភូមិភាគ អាស៊ីអាគ្នេយ៍ ។

### ៣- ភាពខុសគ្នា រវាងចម្លាក់ខ្មែរ និង ចម្លាក់សៀម

ការរញ្ជួយជាដំបូង នៃ ព្រះរាជាណាចក្រខ្មែរ កើតមានឡើងនៅទិស

---

[៦] -The wonderful ruins of Cambodia by Frank Vincent, JR., in, *Journal of the American Geographycal Society of New York*, Vol, 10, ( 1878), pp. 229-252.

៣យ័ព្យ ។

លោកអែម៉ូ នីយេ (Aymonier)[៧] បានសរសេរថា ជនជាតិសៀម មាននៅប្រទេសចិន ក្នុងភូមិភាគនិរតី ហើយគ្មានកំណើតអក្សរសាស្ត្រ ទេ ។ គឺជាជនជាតិមួយ ដែលចិនបានវាយប្រហារ និង រុញចេញពី ប្រទេសចិន ។ លោក អែម៉ូ នីយេ បានបញ្ជាក់ទៀតថា នៅលើ សិលាចារឹកនាឆ្នាំ១២៩២ សរសេរថា ព្រះចៅក្រុងសៀម មានព្រះនាម រាមកំហែង បានហៅគ្រូម្នាក់ឲ្យមកបង្កើតអក្សរសៀម នៅក្នុងឆ្នាំ១២៨៣។

នៅឆ្នាំ ១៩២៦ នៅសារមន្ទីរសៀរនុស៊ី (Cernushi) នៅក្នុង ទីក្រុងប៉ារីស មានធ្វើពិព័រណ៍ពីរូបចម្លាក់ សៀម និង ខ្មែរ ។ ពេល នោះលោក ហ្សក សេដេស (Georges Coedes)[៨] បានបញ្ជាក់ក្នុងអត្ថបទ មួយថា នាពាក់កណ្ដាលសតវត្សទី ១៣ ឯកភាពនយោបាយរបស់សៀម ជា "ព្រឹត្តិការណ៍មួយថ្មីណាស់ នៅក្នុងប្រវត្តិសាស្ត្រ នៃ ឥណ្ឌូចិន" ។ ជនជាតិសៀម បានចេញពីនឹមឥទ្ធិពលរបស់ខ្មែរ ហើយទៅបង្កើតស្រុកមួយ នៅលើទន្លេមេណាម ឲ្យឈ្មោះថា សុខោទ័យ ជាក្រុងសៀមឯករាជ្យ ។ ១សតវត្សក្រោយមក ក្នុងឆ្នាំ ១៣៥០ សៀម បានបង្កើតប្រទេសខ្លួន ឲ្យឈ្មោះថា ក្រុងអយុធ្យា ។

---

[៧]- Le Siam ancien, par Etienne Aymonier, Directeur de l'Ecole Coloniale, in, *Journal Asiatique*, mars-Avril 1903, pp.185-239.

[៨]- Une exposition de sculpture Khmères et Siamoises au Musée CERNUSCHI, par George Coedès in, *Artibus Asiae*, Vol 1, n°3, ( 1926), pp. 190-202.

លោកសេដេស សួរថា វត្ថុចម្លាក់ដែលគេយកពីទីក្រុង ឡុបបុរី ទីក្រុងព្រះបឋម និងទីក្រុងសៀមឯទៀតៗមកតាំងនៅសារមន្ទីរ សៀរនុស៊ី (Cernushi) ក្នុងឆ្នាំ១៩២៦ នោះថា តើជាស្នាដៃចម្លាក់របស់ប្រជាជនសៀម ឬទេ? ។ ចំពោះខ្ញុំ សេដេស ឃើញថាគ្មានន័យទាល់តែសោះ ពីព្រោះ ចម្លាក់ទាំងអស់នោះ មានរចនាបទខ្មែរ ឬ ខ្មែរដើម ឬ ឥណ្ឌា ម៉ាឡេ ដែលបានកើតមានឡើង មុនពេលប្រទេសសៀមមិនទាន់កើតមកផង ។ ចម្លាក់ទាំងអស់នោះ ជនជាតិសៀមមិនបានយកមកជាប់នឹងខ្លួនទេ នៅពេលដែលបានចាកចេញពីស្រុកចិនខាងត្បូង ដែលជាទីកំណើត របស់ខ្លួននោះ ។ ជនជាតិសៀមបានចម្លងក្បួនខ្នាត នៃ សាលាចម្លាក់ខ្មែរ ពីសម័យមុនៗទាំងអស់ ។

គេបានសង្កេតឃើញ រូបចម្លាក់របស់ខ្មែរ មានទំរង់មុខមូល ខ្ញីថ្ងាសទូលាយមិនស្ទូរប៉ោង វង់ចិញ្ចើមមិនកោងដូចដងធ្នូ កន្ទែងសៀតផ្កាស្រុតចុះបន្តិច ច្រមុះធំ រីកបង្គួរ និង មាត់ក្រាស់ទូលាយ រីកជាប់នឹងបបូរមាត់ ។ រូបចម្លាក់របស់សៀម មានសណ្ឋានមុខទ្រវែង មាត់រាងដូចបេះដូង និង ច្រមុះរាងកោង គឺខុសស្រឡះ ពីទ្រង់ទ្រាយ រូបចម្លាក់របស់ខ្មែរ ។

បើស្ដីពីចម្លាក់រូបបុរសវិញ ភាគច្រើនជារាងខ្ញីក្រអាញ ផងខ្លួននៅទទេ គ្រាន់តែយកក្រមា ឬ ក្រណាត់មកបិទបាំងកេរ្តិ៍ខ្មាស តែប៉ុណ្ណោះ ។

វាសនានៃ ទីក្រុងអង្គរ

អ្នកស្រាវជ្រាវពីរនាក់ គឺ លោក ព្យែរ លើហ្វែរ ប៉ុងតាលីស (Pierre Lefèvre Pontalis.)[៩] និង លោក ឡូរ៉ង់ ប៉ាល់មែរ ប្រ៊ីក (Laurence Palmer Briggs)[១០] ជាអ្នកប្រាជ្ញ ជាតិអាមេរិកាំង បាន សរសេរអត្ថបទ និង សៀវភៅជាច្រើន ស្តីពីប្រវត្តិសាស្ត្រ នៃទីក្រុងអង្គរ។

លោក ព្យែរ លើហ្វែរ ប៉ុងតាលីស បានបញ្ជាក់ថា មានជន ជាតិបរទេស បានចូលមក រាតត្បាត បន្តិចម្តងៗ ក្នុងព្រះរាជាណាចក្រ កម្ពុជា នៅតាមព្រំដែនខ្មែរ និង ចិន ។ នយោបាយរបស់ចិន គឺ ទុកឲ្យ ជនបរទេស "ការពារព្រំដែន" របស់ខ្លួន ។ លោក បាននិយាយទៀតថា ជនជាតិសៀម ដែលសាងសង់ក្រុងអយុធ្យា បានត្រូវចំណាយពេលវេលា អស់ ៨សតវត្ស គឺ ៨០០ឆ្នាំ ទើបបានទៅជាអ្នកកាន់កាប់ទឹកដី ជ្រលងភ្នំ និង ភូមិភាគជុំវិញ មាត់ទន្លេមេណាម ។ ពេលនោះ សៀម បានប្រែ ឈ្មោះពីជនជាតិសៀម ទៅជាជនជាតិថៃ ។

ចំពោះលោក ឡូរ៉ង់ ប៉ាល់មែរ ប្រ៊ីក ដែលបានស្រាវជ្រាវឯកសារ របស់អ្នក ប្រវត្តិសាស្ត្រ បព្វជិត គ្រិស្តសាសនា តាយល័រ យ៉ូន (Rev.J. Taylor Jones) ជាភាសាអង់គ្លេស លោក វីលម៉េរើយ

---

[៩]- L'invasion Thaïe en Indo-Chine par Mr. Pierrre Lefèvre Pontalis, in, *T'oung Pao*, Vol. VIII, 1897, pp.53-78 ; *T'oung Pao*, série II, vol.10, 1909, pp. 495-512.

[១០]- Siamese Attacks on Angkor Before 1430, by Lawrenre Palmer Briggs, in, *The Far Eastern Quarterly*, Vol, N°1, ( Nov 1948), pp. 3-33.

(A de Villemereuil) លោក ហ្សង់ មួរ៉ា (Jean Moura) និង លោក ហ្វ្រង់ស៊ីស ហ្គានីញេ (Francis Garnier) ជាភាសាបារាំង បាន សរសេរថា: ១-សៀមបានចូលវាយយកទីក្រុងអង្គរ បានទាន្នំ ១៤៣០-១៤៣១ ។ ២-ពេលនោះ ស្ដេចសៀម ព្រះនាម បរមរាជា ទី២ ។ ៣- ស្ដេចខ្មែរ ព្រះនាម ព្រះបាទធម្មាសោក ។ ៤-ចម្បាំងនោះ អស់រយៈកាល ៧ខែ ។ ៥-មន្ត្រីខ្មែរឈ្មោះ កែវគីរ ឬ គីឡូ និង សៀម-តាយ ឬ ធី ព្រមទាំងព្រះសង្ឃពីរអង្គ (យោងតាមឯកសារ របស់ព្រះ-បាទអង្គ អេង) បានចូលដៃ ជាមួយសៀម ។ ៦-ស្ដេចខ្មែរ សោយ-ព្រះទីវង្គត ក្នុងសង្គ្រាមនោះ ។ ៧-ស្ដេចសៀម ដាក់ព្រះរាជបុត្រ ព្រះនាម ឥន្ទបុរី ឲ្យសោយរាជ្យនៅទីក្រុងអង្គរ ។ ៨-ទ័ពសៀម បានប្រមូលទ្រព្យសម្បត្តិ និង វត្ថុ ជាទីសក្ការៈ យ៉ាងសន្ធឹកសន្ធាប់ យកទៅប្រទេសសៀម ។ ស្ដេចខ្មែរ ព្រះនាម ពញាយ៉ាត បានឡើងកាន់អំណាចនៅទីក្រុងអង្គរ បន្ទាប់ពីបានបណ្ដេញសៀមចេញអស់ ហើយ លើកព្រះរាជធានី មកតាំងនៅ ទីក្រុងលង្វែកវិញ ។

បើតាមឯកសារ របស់លោក ហ្ស៊ក ម៉ាស្ប៉េរ៉ូ (Georges Maspéro) គឺពេលបែក ទីក្រុងអង្គរ ប្រទេសកម្ពុជា បានចុះចាញ់គេ និង ត្រូវខូចខាតខ្ទេចខ្ទីជាខ្លាំង (បដិវត្តន៍ ឬ វិបត្តិផ្ទៃក្នុង ក៏មានទៅមែន) ថ្វីត្បិតតែគ្មានឯកសារប្រវត្តិសាស្ត្រណាបញ្ជាក់ឲ្យបានច្បាស់លាស់ក្ដី ។ លោកបានបញ្ជាក់ទៀតថា នេះជាការសន្និដ្ឋាន ឬ ក៏ជាការសន្មត តែប៉ុណ្ណោះ ព្រោះស្ដេច-ខ្មែរ ឥតបានបោះបង់ ទីក្រុងអង្គរទេ ដោយគ្រាន់តែយល់ថា ព្រះអង្គ

មិនអាចយក ទីក្រុងអង្គរ មកធ្វើជា ព្រះរាជធានី នៃប្រទេសកម្ពុជា ទៀតទេ ។

សេចក្ដីបញ្ជាក់

នាឆ្នាំ១៩៩៥ លោក ក្រែក ឡូកាដ (Craig A. Lockard) (១១) បានស្រាវជ្រាវឃើញច្បាស់ថា ប្រជាជនខ្មែរដែលបានមកស្ថិតនៅ ក្នុងភូមិភាគយើងសព្វថ្ងៃនេះ ចាប់តាំងពី ១.៥០០ ឆ្នាំមុនមកម្ល៉េះ គឺមុនគ្រិស្តសករាជ និងមុនជនជាតិឯទៀតៗទាំងអស់ ។

ប្រជាជនខ្មែរបានរៀបចំប្រទេស ស្របទៅតាមអារ្យធម៌របស់ខ្លួន សូម្បីតែអ្នកដំណើរបរទេស ក៏មានការកោតសរសើរ ពីទំនៀមទម្លាប់ ប្រពៃណី វប្បធម៌ ដែលមានស្ត្រីខ្មែរជួយប្រឈមមុខ យ៉ាងរឹងមាំ ដើម្បីការពាររក្សាទុក ឲ្យដល់កូនចៅជំនាន់ក្រោយទៀត ។

ខ្លួនខ្ញុំផ្ទាល់ យល់ឃើញថា បើពេលណាដែលខ្មែរយើងបាត់អារ្យធម៌ ពេលនោះហើយដែលខ្មែរយើងបាត់ពូជ រលាយចូលជាតិដទៃ ឬ ទៅជាជនអនាថា រត់រកជំរកគ្រប់ទីកន្លែង ដើម្បីនឹងបានរស់រានមានជីវិត នឹងគេ ដោយមិនបានយល់ច្បាស់ថា ខ្លួនជាជាតិខ្មែរ ឬក៏ជាសាសន៍ អ្វីទៀតផង ។ សូមបងប្អូនខ្មែរយើង ភ្ញាក់រឭកឡើង ។

---

(១១)- Integrating Southeast Asia into the framework of World History : The Period before 1500, by Craig A. Lockard, in, *The History Teacher*, Vol 29, N° 1, ( Nov. 1995), pp. 7-35.

ខ្ញុំព្រះករុណា ខ្ញុំ សូមថ្លែងអំណរគុណជាអនេកប្បការ ដល់ព្រះអង្គគ្រូ ធិន ភេន ឥន្ទប្បញ្ញោ ដែលបានលើក រំលឹកឡើងពី "ខ្មែរមានពូជ" មកអធិប្បាយក្នុងពេលនេះ ។

ខ្ញុំព្រះករុណា ខ្ញុំ សូមថ្វាយបង្គំ គោរពដឹងគុណ ចំពោះព្រះគ្រូ ធិន ភេន ព្រះគ្រូ សារ សាស្រ្ត ដែលតែងតែដាស់តឿន ប្រៀនប្រដៅ ពន្យល់ពីន័យរបស់ "ខ្មែរមានពូជ" ។

ខ្ញុំព្រះករុណា ខ្ញុំ សូមថ្លែងអំណរគុណ ដល់ព្រះអង្គ ពេជ្រ សាម៉ុន ដែលមានសន្តានចិត្ត ដ៏ថ្លៃថ្លា ដែលបានដឹកនាំការប្រជុំ និង ជួយកិច្ចការ ផ្សេងៗ រហូតបានសម្រេចលទ្ធផល គួរជាទីគាប់ចិត្តនេះ ។

ខ្ញុំព្រះករុណា ខ្ញុំ សូមបួងសួង គោរពរំលឹកគុណ ឪពុក ម្តាយ គ្រូបាធ្យាយ និង ព្រលឹងនៃបុព្វបុរសខ្មែរទាំងឡាយ ដែលបានចែកឋាន ទៅហើយ សូមលោកជួយថែរក្សា ការពារ ទ្រទ្រង់ ទ្រព្យសម្បត្តិ "ខ្មែរមានពូជ" ឲ្យបានគង់វង់ជានិរន្តរ៍ តរៀងទៅ ៕

ចាយ សិរីវុឌ្ឍ




Zones d'influence des civilisations indienne et chinoise et mouvements de populations en Indochine.

Prolégomènes à l'histoire khmère par Fabricius,
In, France-Asie, n° 164, Nov-Décem 1960, pp.1451-1472

354 THE FAR EASTERN QUARTERLY




*Cambodia in the Fifteenth and Sixteenth Centuries*

A Sketch of Cambodia History, by Lawrence Palmer Briggs, in, Far Eastern Quarterly, Vol.6, n°4, August 1947, pp. 345-363.




*The Funanese Empire under Fan Shih-man*

The khmer Empire and the Malay Peninsula by Lawrence Palmer Briggs, in, Far Eastern Quarterly, Vol 9, n° 3 , May 1950, pp. 256-305.

# SOUTHEAST ASIA BEFORE 1500 CE




Integrating Southeast Asia into the framework of World History : The Period before 1500, by Craig A. LocKard, in, The History Teacher, Vol 29, n° 1, ( Nov.1995), pp. 7-35.

-mm-

L'HISTOIRE

LE SIAM



• **LE SIAM AVANT LES SIAMOIS**

L'HISTOIRE

LE SIAM



*Les Syâms, mercenaires, dans les bas-reliefs de la galerie sud, aile ouest du temple d'Angkor Vat (milieu du XII<sup></sup>e s.)*

Le Siam par Michel Jacq-Hergoualc'h,
Société d'édition le belles Lettres, 2004.



art khmer classique



tête de bouddha, Ecole de Lopburi.Thaïlande

# ការអប់រំ នៃ ពូជពង្សខ្មែរ

## ដោយ ឌី ការ៉េត

ខ្មែរមានពូជ គឺខ្មែរដែលកើតមក បានទទួលការអប់រំ ក្នុងគំនិតស្មារតី និង ទំនៀមទម្លាប់ល្អ នៃ ប្រជាជនខ្មែរ ។

ការស្រាវជ្រាវជាបន្ថែមថ្មីៗ ក្នុងប្រវត្តិសាស្ត្រ បានបង្ហាញថា ប្រជាជនខ្មែរ (និងប្រជាជន"មន") មានពូជពង្សបន្តពី ប្រជាជនមួយ ហៅថា "មុនឌះ" (Monda) ដែលជាប្រជាជនរស់នៅប្រទេសឥណ្ឌា មុនគេបំផុតកាលពីជាង ៣០.០០០ ឆ្នាំ មុនគ្រិស្តសករាជ (គ.ស.) ។ ដោយមិនព្រមទទួលរងអំណាច នៃ ពួកឈ្លានពានបរទេស ជាបន្តបន្ទាប់ ចាប់ពីម្ដុំឆ្នាំ ១០.០០០ មុន គ.ស. ប្រជាជនខ្មែរ បាននាំគ្នាចេញពីប្រទេសឥណ្ឌា បន្តិចម្ដងៗ ហើយមកតាំងទីលំនៅ នៅលើទឹកដីខ្លួនថ្មីសព្វថ្ងៃ ពីម្ដុំឆ្នាំ ៦.០០០ មុន គ.ស. ។ ពួក "មម" (Mom) ហៅថា "មន" (Môn) ដែលជាប់ខ្សែស្រឡាយនឹងខ្មែរ បានមកដល់ភូមា នៅម្ដុំឆ្នាំ ៣.០០០ មុន គ.ស. ។ ហេតុនេះ ជនជាតិខ្មែរ បានមករស់នៅលើទឹកដីសព្វថ្ងៃ មុនពួកសៀម ពួកឡាវ ពួកយួន ពួកចាម ចំនួនរាប់ពាន់ឆ្នាំ ដោយមានភាសា មានវប្បធម៌ មានសាសនា មានចំណេះវិជ្ជា របស់ខ្លួនផ្ទាល់ ហើយបានសាងសង់ប្រទេសខ្លួន ហៅថា "ស្រុកខ្មែរ" យ៉ាងមាំមួនជាស្រេច ។ លុះចាប់ពីដើមគ្រិស្តសតវត្សទី១ ទើបខ្មែរមានការទាក់ទងជាថ្មី ជាមួយនឹងពួកជនជាតិឥណ្ឌា ដែលមានឥទ្ធិពល មកនៅដល់ប្រទេសម៉ាឡេ នាពេលនោះ ។

នៅក្នុងប្រវត្តិសាស្ត្រ ខ្មែរសព្វថ្ងៃ យើងបានដឹងខ្លះៗ តែអំពីសម័យ ហ្វូណន (នគរភ្នំ) សម័យចិនឡា សម័យអង្គរ ឬ កម្ពុជា ។ ប៉ុន្តែ នៅមុនសម័យ ហ្វូណន "ស្រុកខ្មែរ" ជារដ្ឋខ្លាំងពូកែមួយទៅហើយ ដែលគោរពលទ្ធិពិសេសមួយ ហៅថា "មត្តេយ្យកា" (មេ ម្ដាយ ឬ ស្រី ជាធំ ជាអ្នកដឹកនាំ - Le matriarcat ) និងកាន់សាសនាមួយ ដែលគោរពបូជា "មេ បា" "នាងគង្ហីងព្រះធរណី និង ព្រលឹងក្រពើ" "អ្នកតា" ជាអាទិ៍ ។ ជនជាតិខ្មែរ បានគោរពបូជាគុណបារមីទាំងនេះ នៅគ្រប់សម័យ ជាបន្តបន្ទាប់ រហូតមកដល់សព្វថ្ងៃ ។ នេះ សឲ្យឃើញថា រហូតមកដល់សព្វថ្ងៃ ប្រជាជនខ្មែរជា "ពូជ" តែមួយ ជានិច្ច ។

## ទេពកោសល្យនៃ ប្រជាជនខ្មែរ

នៅក្នុងអតីតកាល គំនិតស្មារតី និង ចំណេះវិជ្ជា មិនមែនបានកើតឡើង ក្នុងរយៈតែ ២០-៣០ ឆ្នាំ ឬ ១០០ ឆ្នាំទេ ។ ប្រទេសឥណ្ឌា ឬ ចិន ដែលមានអារ្យធម៌ខ្ពស់ហើយ នៅពេលនោះ ក៏មិនដែលបានមកគ្រប់គ្រង ឬដឹកនាំប្រជាជនខ្មែរទេ ។ តែប្រជាជននេះ មានទេពកោសល្យខ្ពស់ ដោយបានបង្កើតសម្រាប់ជាតិសាសន៍ខ្លួនឯងនូវប្រព័ន្ធមួយ ដឹកនាំសង្គម និងប្រទេស (គឺរបប មត្តេយ្យកា) សាសនាមួយរបស់ខ្លួន (មេ-បា និង ព្រះធម្មជាតិ) តួអក្សរ និង តួលេខមួយចំនួន (ដែលជាសញ្ញាផ្តុំគ្នា រវាង ព្យញ្ជនៈ និង ស្រៈ ដើម្បីបង្កើតជាពាក្យ គឺមិនមែនជាសញ្ញារូបភាពផ្តុំគ្នាទេ) និងបច្ចេកទេសធ្វើស្រែ-ចំការ ការនេសាទ ការងារលោហធាតុ (ដែក

ស្ពាន់ ទង់ដែង មាស ប្រាក់... ) ។ នៅដើមសម័យ ហ្វូណន ពួកអ្នកដំណើរចិន បានឃើញថា (ខ្មែរ ជាជាងទង (ធ្វើគ្រឿងមាស-ប្រាក់) យ៉ាងប៉ិនប្រសប់ ចេះត្បាញសំពត់យ៉ាងល្អប្រណីត ជាអ្នកចេះកែខៃទឹកដីយ៉ាងចំណាន ដើម្បីកសិកម្ម ចេះធ្វើសំពៅដើរសមុទ្រ មានប្រវែង ៣០ម៉ែត្រ..." ។

នៅសម័យ ហ្វូណន (ឬ នគរភ្នំ) ចិនឡា និង អង្គរ បច្ចេកកសិកម្ម សំណង់ ចម្លាក់ និង សិល្បៈផ្សេងៗ បានចំរើនជាខ្លាំងទៀត ដោយសារខ្មែរបានស្រង់យក គំនិតស្មារតី និង ចំណេះវិជ្ជា ពីឥណ្ឌា ប៉ុន្តែ ដោយរក្សាចរិតដើម នៃ ជាតិសាសន៍ខ្លួនជានិច្ច ។ ខ្មែរពូកែខាងវិទ្យាសាស្ត្រ ជាពិសេសគណិតវិទ្យា រូបវិទ្យា តារាវិទ្យា និង សំណង់ ។ ខ្មែរបានបង្កើតរបៀបរាប់លេខពន្ទ ដែលមានមូលដ្ឋានប្រាំ (១,២,៣,៤,៥,) ហើយបំបែកដល់លេខដប់ ។ ក្នុងវិស័យអក្សរសាស្ត្រ និង សិល្បសាស្ត្រ ខ្មែរបានបង្កើតកំណាព្យ និង ចំរៀង ជាច្រើនបែបបទ ហើយតន្ត្រី និង របាំខ្មែរមានឈ្មោះល្បីល្បាញឆ្លងប្រទេស ឆ្លងជាតិសាសន៍ ឆ្លងសតវត្ស មកដល់សព្វថ្ងៃ ។ រីឯវិជ្ជាធ្វើម្ហូបខ្មែរ ក៏ជាស្នាដៃយ៉ាងធំមួយទៀត ដែលត្រូវបានជនជាតិឯទៀត រៀនធ្វើតាមរហូតមកដែរ ។

## ប្រពៃណីខ្មែរ នៃ ការអប់រំខ្មែរ

ទេពកោសល្យទាំងនេះ បានបង្កើតមានដោយសារជនជាតិខ្មែរចូលចិត្តរៀនសូត្រវិជ្ជា ហើយមានស្មារតីផ្ចិតផ្ចង់ការងារណាស់ ។ នៅសម័យ

ហ្វូណន ក្នុង គ.ស. ទី៣ យើងបានដឹងថា មានឯកសារជាច្រើនណាស់ ស្តីអំពីវិជ្ជា និង ការងារផ្សេងៗ ដែលគេរក្សាទុកក្នុងបណ្ណាល័យនានា ។ នៅក្នុងលទ្ធិព្រាហ្មណ៍សាសនា គេរៀនសូត្រជាច្រើនបំផុត អំពីគម្ពីរ“វេទ” (les Vedas) ជាភាសាសំស្ក្រឹត ដែលនៅក្នុងនោះ មានវិជ្ជាសព្វយ៉ាង ជាអាទិ៍ គឺ សាសនា អក្សរសាស្ត្រ វេយ្យាករណ៍ ច្បាប់ (នៃ អាទិទេព) វេជ្ជសាស្ត្រ គណិតសាស្ត្រ តារាសាស្ត្រ ស្ថាបនកម្ម សេដ្ឋសាស្ត្រ កសិកម្ម នយោបាយ សង្គ្រាមសាស្ត្រ និង សិល្បសាស្ត្រ ឬ បច្ចេកទេស ផ្សេងៗទៀត ។ ការចេះដឹងរបស់អ្នកប្រាជ្ញខ្មែរ នាសម័យនោះ បានលេចឮទៅទីឆ្ងាយៗណាស់ ។ នៅសតវត្សទី៣ ប្រទេសចិន បាននិមន្តមហាភិក្ខុខ្មែរ ខាងពុទ្ធសាសនា ជាច្រើនអង្គ ឲ្យទៅបង្ហាត់ បង្រៀនព្រះពុទ្ធសាសនា នៅប្រទេសគេ ។ ក្រោយមកទៀត ចិនបាននាំយកអ្នកតន្ត្រីខ្មែរ ឲ្យទៅសំដែង និង បង្ហាត់បង្រៀនពួកអ្នកតន្ត្រីគេដែរ ។ នៅក្រុងអង្គរ មានពួកអ្នកប្រាជ្ញពីឥណ្ឌា និង ជ្វា មកសិក្សានៅសាកលវិទ្យាល័យខ្មែរ ជាបន្តបន្ទាប់ ។ នៅសម័យនោះ ស្រីខ្មែរ ក៏មានចំណេះវិជ្ជាខ្ពង់ខ្ពស់ មិនចាញ់ប្រុសទេ ។

នៅសម័យក្រោយៗមកទៀត ខ្មែរក៏តែងតែអប់រំកូនចៅខ្លួន ក្នុងគោលការណ៍ធំៗពីរ ជានិច្ច គឺកូនស្រី ប្រុស -

១-ត្រូវយល់ថា ចំណេះវិជ្ជា ជាប្រភពនៃទ្រព្យសម្បត្តិ និង ឫទ្ធានុភាព ហេតុនេះ គេត្រូវខំស្វែងរកចំណេះវិជ្ជា ជានិច្ចកាល ។

២-ត្រូវកាន់ខ្ជាប់ខ្លួន នូវវិស័យសីលធម៌ និង វិស័យកិរិយា មារយាទ

ក្នុងជីវភាពផ្ទាល់ខ្លួន និង ជាមួយអ្នកផងក្នុងសង្គម ។ (នេះគឺដើម្បីរក្សា "ឯកភាព"នៃសង្គម ដោយខ្មែរបានគិតថា មនុស្សម្នាក់ៗត្រូវដឹងអំពី"ទីកន្លែង" របស់ខ្លួន នៅក្នុងសង្គម គឺ ក្នុងគ្រួសារ ក្នុងភូមិស្រុក ឬ ក្នុងសហគមជាតិ បើពុំដូច្នោះទេ អ្នកនោះឯង "មនុស្សថ្កជាតិ" ។ ប៉ុន្តែ "ទីកន្លែង"នោះ អាចផ្លាស់ប្តូរ ដោយសារគុណសម្បត្តិ ឬ គុណវិបត្តិ ជាបន្ទាប់មក របស់មនុស្សនោះដែរ) ។

## វិន័យផ្ទាល់ខ្លួន និង វិន័យក្នុងសង្គម

លទ្ធិមត្តេយ្យកាខ្មែរ នៅមានអានុភាពជាខ្លាំង នៅសម័យ ហ្វូណន (នគរភ្នំ) រហូតដល់សម័យអង្គរជំ នៃ ព្រះបាទជ័យវរ្ម័ន ទី៧ ។ នៅសម័យទាំងនោះ ស្តេចដែលដណ្តើមអំណាចបាន ដោយកម្លាំងឃោរឃៅ តែងតែយកមហេសី ឬ បុត្រីស្តេចដែលចាញ់ខ្លួននោះ ធ្វើជាមហេសីខ្លួន ដើម្បីឲ្យរាជ្យខ្លួន មានលក្ខណៈត្រឹមត្រូវ ស្របច្បាប់ប្រពៃណី ។ ដោយសារអានុភាពនេះ ខ្មែរទូទៅ តែងប្រាថ្នាចង់បានកូនស្រី ជាងកូនប្រុស ព្រោះកូនស្រី ជាអ្នកទទួលមរតកទ្រព្យសម្បត្តិ ហើយនឹងនៅថែរក្សាម្តាយឪពុកជានិច្ច ។ នៅគ្រប់សម័យ ប្រជាជនខ្មែរគោរពសិទ្ធិសេរីភាពរបស់ស្រី ដូចគ្នានឹងប្រុស យ៉ាងហោចណាស់ចំពោះភ្នែកសង្គម ។ ចំណុចទាំងនេះ ខុសអំពីទស្សនៈរបស់ឥណ្ឌា ឬ ចិន ។ ម្យ៉ាងទៀត ខ្មែរជាមហាគ្រួសារតែមួយ ដែលសមាជិកហៅរកគ្នា ថាជាបង ប្អូន ពូ មីង យាយ តា... ដូចនៅក្នុងគ្រួសារផ្ទាល់របស់ខ្លួន ។

តាំងពីកំណើត រហូតដល់អាយុ ៧ ឬ ៨ ឆ្នាំ កូនខ្មែររស់ក្នុងសេរីភាព នៅក្នុងជំរុំគ្រួសារផង និង ក្នុងបរិវេណនៃអ្នកជិតខាង នៅក្នុងភូមិស្រុក ជាមួយផង ។ ម្ដាយ ឪពុក បង ៗ និង អ្នកជិតខាង តែងជួយបង្ហាត់បង្រៀនកុមារតូចៗ ឲ្យលេងល្បែង ឲ្យចេះហែលទឹក ឲ្យរៀនធ្វើកិច្ចការបន្តិចបន្តួច ។ ចាប់ពីអាយុ ៧ ឬ ៨ ឆ្នាំ កូនប្រុសៗ ត្រូវទៅរៀនអក្សរលេខនព្វន្ត ការងារជាង និង ធម៌អាថ៌ នៅសាលា (អាស្រម វត្ត) ។ យុវជន ដែលមានប្រាជ្ញាឈ្លាសវៃ អាចនឹងបន្តការសិក្សា ជាមួយនឹងគ្រូ-អាចារ្យ នៅទីក្រុងទៀត ។

ប៉ុន្តែ ជនជាតិខ្មែរតែងយកចិត្តទុកដាក់ជាបឋម ក្នុងការអប់រំសីលធម៌និងកិរិយា មារយាទ របស់កូនស្រី ប្រុស ។ ការអប់រំនេះ មានទ្រង់ទ្រាយពីរយ៉ាង គឺមានការរៀបចំពិធីផ្សេងៗផង និង ការបង្រៀនក្បួន "ច្បាប់" សាស្ត្រ គម្ពីរផ្សេងៗ ឲ្យចេះចាំស្ទាត់ផង ។

ពិធីអប់រំ តាមទំនៀមទម្លាប់ មានរៀបចំហូរហែ ក្នុងឱកាសអាពាហ៍ពិពាហ៍ខ្មែរ ដូចជាពិធីសូមការអនុញ្ញាតអំពីមេ-បា ពិធីគោរពក្រុមគ្រួសារទាំងសង្ខាង ពិធីកាត់សក់ ពិធីខាត់ធ្មេញ ពិធីបង្វិលពពិល ពិធីបង្ហាញគូស្រករថ្មី ដល់សហគមន៍ភូមិស្រុក ។ល។ ពិធីអាពាហ៍ពិពាហ៍ខ្មែរ ជាការផ្សំផ្គុំមនុស្សពីរនាក់ ជាគូនឹងគ្នាហើយ តែក៏ជាពិធីបង្រួបបង្រួមគ្រួសារពីរព្រមទាំងក្រុមញាតិ "ទាំង ៧ សន្ដាន" សង្ខាង និង អ្នកភូមិស្រុកទាំងពីរផង ។ ពាក្យថា "មេ បា" មិនមានន័យត្រឹមតែម្ដាយ ឪពុក ជីដូន ជីតា ទេ ។ "មេ" គឺធាតុឬព្រលឹងដែលផ្ដល់ជីវិតឬឧបត្ថម្ភជីវិត ។

"បា" គឺជាតុឬព្រលឹងដែលការពារជីវិត ។ "អ្នកតា" ជាព្រលឹងនៃបុរសដែលការពារភូមិស្រុក ។

ការអប់រំមួយផ្នែកទៀត គឺការបង្រៀន"ច្បាប់" ទូន្មានខ្លួន ជាច្រើនចំពូក ។ កម្រង"ច្បាប់" ទាំងនោះ ពិតជាមរតកសីលធម៌ និង ជាសម្បត្តិសតិបញ្ញាមួយ របស់ប្រជាជនខ្មែរ ដែលគេបានតាក់តែង និង បង្រៀនត្អីត្អាពីស្រករមួយទៅស្រករមួយទៀត ជាច្រើនរយឆ្នាំមកហើយ (ប្រហែលពីសម័យលង្វែកមក ឬ ពីមុននោះផង) ។ គេបានតែង"ច្បាប់" ទាំងអស់នោះ ជាបទកំណាព្យផ្សេងៗ ដើម្បីឲ្យអ្នកស្តាប់ចាប់ចិត្ត និង ចងចាំសេចក្តីដោយងាយ ។ "ច្បាប់" ដែលគេស្គាល់ច្រើន *គឺច្បាប់ប្រុស ច្បាប់ស្រី ច្បាប់កូនចៅ ច្បាប់កេរ្តិ៍កាល ច្បាប់ក្រម ច្បាប់ត្រីនេតិ ច្បាប់ពាក្យចាស់ ច្បាប់ទូន្មានខ្លួន ច្បាប់វិធុរបណ្ឌិត ច្បាប់រាជនេតិ(ឬច្បាប់ព្រះរាជសម្ភារ)*។ "ច្បាប់" ទាំងនោះ ជាកម្រងវិន័យ សំរាប់កសាងគំនិតស្មារតី នៃ បុគ្គលម្នាក់ៗហើយ ប៉ុន្តែ សំខាន់បំផុត គឺវិន័យដែលបុគ្គលម្នាក់ៗនោះត្រូវកាន់ក្នុងកិរិយា មារយាទខ្លួន ចំពោះអ្នកនៅជុំវិញខ្លួន មានម្តាយ ឪពុក បងប្អូន គ្រូអាចារ្យ ប្តី ឬ ប្រពន្ធ មនុស្សចាស់ទុំ ឬ អ្នកមានអំណាចដឹកនាំ ។

ក្នុងវិន័យផ្ទាល់ខ្លួន កូនខ្មែរត្រូវជាអ្នកឧស្សាហ៍ធ្វើការងារ ឧស្សាហ៍រកភោគផល សំរាប់សេចក្តីត្រូវការរបស់ខ្លួន និង គ្រួសារ ចេះគិតគូរថែរក្សាផ្ទះសម្បែង និង ទ្រព្យសម្បត្តិខ្លួន កុំលួចប្លន់គេ កុំសុំទានគេ... -

*-កុំខ្ជិលកុំប្រអូស ទៅងូសរត់សុំគេ គេមិនឲ្យឯងទេ តែគឺមោះព្រោះខ្ជិលដាំ*

*-ទោះធ្វើស្រែចំការ ឲ្យឧស្សាហ៍មើលថែទាំ កុំខ្ជិលកុំប្រចាំ ចបចូកជីកស្មៅវល្លិ៍ផង*

*-កុំទុកដៃទទេ ដាំងទំនេរ ពោចស្ទៅព្រៅ ខាងផ្ទះខាងលំនៅ ឲ្យវាលកាលកើត សុខា ។ (ច្បាប់ប្រុស)*

ជាមួយគ្នានេះ ច្បាប់ទាំងអស់ប្រាប់ឲ្យជៀសវាងអំពើ“ឆ្កួត”បី គឺ ការសប្បាយនឹងភេទ និង គ្រឿងស្រវឹង និង ល្បែងភ្នាល់គ្នា -

*-លោកថាឆ្កួតបី ឆ្កួតមួយនឹងស្រី ឆ្កួតមួយនឹងស្រា ឆ្កួតមួយនឹងល្បែង អំពើពាលា ឆ្កួតនេះហៅមហា ឆ្កួតក្រៃកន្លង ។* (ច្បាប់ កូនចៅ)

នៅក្នុងសង្គម កូនខ្មែរត្រូវដឹងថា “សម្ដី សជាតិ មារយាទ សត្រកូល” ឬថា“សម្ដីជាឯក លេខជាទោ អក្សរជាត្រី” គឺគេត្រូវមាន ឥរិយាបថទន់ភ្លន់(ដូចកុជង្គ) មានភាពរាបសា មានការគោរព ហើយ សំខាន់បំផុត គេត្រូវនិយាយស្ដី ដោយភាសាសមគួរ ពីរោះ មិនប្រើពាក្យ ព្រហើន ឬពាក្យ“បាតផ្សារ” -

*-រៀនបទរៀនបាទចាស កុំប្រឡាសលើរៀមច្បង ស្រដីនឹងអ្នកផង ពាក្យឲ្យគួរកុំងងរ៉ី ។*

*-អឺអើអញដាច់សាច់ ឆ្គងពាក្យពេចន៍គេស្រដី ដើមជៀលឲ្យអប្រិយ ស្រដីថាកូនអត់ពូជ ។ (ច្បាប់ ប្រុស)*

ការគោរព និង ការដឹងគុណ ចំពោះម្ដាយ ឪពុក និង គ្រូអាចារ្យ ត្រូវ មានកំរិតខ្ពស់បំផុត -

*-ព្រះជនកព្រះជននី បើនឹងស្រដី ប្រសើរពេកពន់ ថាភ្នំព្រះសុមេរុ នោះហោងមហាធ្ងន់ បើថានឹងគណន៍ ពុំអាចកន្លង ។ (ច្បាប់ក្រម)*

*-កុំធ្វើរាយមាយ នឹងត្រូវចាញ្យាយ ទុកស្មើអម្ចាស់ សង្វាតសរសេរ ស្ងួតរៀនឲ្យណាស់ ប្រាជ្ញាយល់ច្បាស់ នាំញាតិទាំងឡាយ ។*

*-វិជ្ជាចាញ្យាយ អាចឲ្យពណ្ណរាយ មានរូបរស្មី ហើយឲ្យរុងរឿង អស់បញ្ញត្តិន្ទ្រីយ៍ ស្មើព្រះជនទី ជនកសោតហោង ។ (ច្បាប់ក្រម)*

អ្នកចេះដឹង អ្នកមានទ្រព្យធន ត្រូវជួយឃឹតយោងអ្នកខ្វៅ ជួយឧបត្ថម្ភអ្នកក្រីក្រ ។ សាមគ្គីភាពនេះ ជាករណីយកិច្ចសីលធម៌ នៃ កូនខ្មែររាល់រូប ដែលត្រូវពឹងពាក់គ្នាទៅវិញទៅមក ជានិច្ច -

*-អ្នកមានរក្សាខ្សត់ ដូចសំពត់ព័ទ្ធពីក្រៅ អ្នកប្រាជ្ញរក្សាខ្វៅ ដូចសំពៅ- នូវសំពាន ។*

*-អ្នកខ្ពស់រក្សាទាប ដោយសភាពធម៌បុរាណ អ្នកថ្លៃតរក្សាឃ្លាន នាអ្នក-រុងរក្សាធ្លារ ។*

*-រក្សាទៅមករឹង ឥតកំដឹងអស់អម្បាល ចំណេរចេរកាន់កាល ដូចរបង-ស្រោសបន្ទា ។ (ច្បាប់ពាក្យចាស់)*

*-ហែអស់កូនចៅ តំណក្រោយទៅ ត្រកូលវង្សា ចូរចេះរាប់រក ស្រករគ្នីគ្នា ខុសគាប់កាចជា អត់ខិនត្រងរង ។ (ច្បាប់កូនចៅ)*

ជាមួយគ្នានេះ មនុស្សម្នាក់ ៗ ត្រូវដឹងច្បាស់ នូវការទទួលខុសត្រូវរបស់ខ្លួន ត្រូវចេះទទួលស្គាល់ការភ័ន្តច្រឡំ ឬកំហុសរបស់ខ្លួន ហើយចេះចែករំលែកទុក្ខ និង សុខ ជាមួយញាតិមិត្តខ្លួនផង -

*-ពាក្យចាស់ពាក្យពីព្រេង ទោសខ្លួនឯងមើលពុំយល់ ទោសគេតូចសោតសល់ រមិលយល់ប៉ុនទាំងភ្នំ ។*

*-ចូលព្រៃសត្វសាហាវ រកអំពាវគ្នាមកជុំ ដល់បានស្គរទឹកឃ្មុំ ពួនក្នុងផ្ទះស៊ីម្នាក់ឯង*

*-បានហើយចង់បានទៀត ធៀតហើយធៀតពុំគិតឈ្នេង មើលយល់តែមុខឯង មិនយល់គេឯទៀតផង ។ (ច្បាប់ពាក្យចាស់)*

ប៉ុន្តែ គេត្រូវមានការប្រយ័ត្ន ក្នុងការសេពគប់ជាមួយអ្នកឯទៀត ជានិច្ចដែរ -

*-កុំកាចកុំស្លូតពេក កុំចំអេករៀនរហ័ស កុំខ្លាចកុំហ៊ានណាស់ ឲ្យរំពឹងរំពៃគ្រប់ ។*

*(ច្បាប់ប្រុស)*

*-កុំទុកចិត្តបរទេស កុំទុកចិត្តអភិទេស្រ្តម៍ កុំទុកចិត្តអភិព្រាយ ប្រើស្នាំលែងខ្ពស់ រំពឹងឲ្យឆ្ងាយ ស្តាប់ពាក្យបរិយាយ បណ្ដិបមេជី ។ (ច្បាប់ព្រះរាជសម្ភារ)*

*-អ្នកមួយចែចូវ រអែរអ្នូវ រៀចរេបូស្សា បញ្ចើចបញ្ចើ ពាក្យពើមាយា ដូចកលផ្លែល្វា ល្អល្អះតែក្រៅ ។...*

## ទិន្ន័យនយោបាយ

នៅក្នុងជំនឿលើ “មេ បា” ប្រជាជនខ្មែរយល់ថា វាសនារបស់ខ្លួនពឹងពាក់ទាំងស្រុង លើអ្នកដឹកនាំស្រុក គឺមហាក្សត្រ និង នាម៉ឺនមុខមន្ត្រី ។ ហេតុនេះ ឧត្តមគតិខ្មែរ ក្នុងលទ្ធិនយោបាយផ្សេងៗ (មគ្គេយ្យកា ព្រហ្មញ្ញសាសនា ពុទ្ធសាសនា) មហាក្សត្រ និង មន្ត្រីរដ្ឋ មានកាតព្វកិច្ចបឋមបំផុត គឺផ្តល់ និង ការពារសេចក្តីចំរើនជីវភាព ឲ្យប្រជាជន(រាស្ត្រ-ទាស) ។ ឧទាហរណ៍ ពីសម័យអង្គរ គឺមហាក្សត្រខ្មែរ ខិតខំណាស់រកវិធីទប់និងចែករំលែកទឹក សំរាប់រាស្ត្រធ្វើស្រែចំការ (មានការសាងបារាយ ប្រកបដោយបច្ចេកទេសខ្ពស់ ជាអាទិ៍) ខំធ្វើផ្លូវគមនាគមន៍គោកនិងទឹក សំរាប់រាស្ត្រធ្វើដំណើររកស៊ី ខំសាងសង់មន្ទីរព្យាបាលរោគ

សំរាប់ថែទាំសុខភាពរាស្ត្រ ខំសាងសង់សាលារៀន សំរាប់បណ្តុះបណ្តាលចំណេះវិជ្ជារបស់រាស្ត្រ ។ល។ ក្នុងគ្រប់លទ្ធិ មហាក្សត្រ ត្រូវគ្រប់គ្រងរដ្ឋ និង ប្រជាជន តាមបទបញ្ញាច្បាប់(ព្រះធម៌) ឬ"រដ្ឋធម្មនុញ្ញ) មិនមែនតាមអំពើចិត្តខ្លួនទេ ។ នៅសម័យនគរភ្នំ និង អង្គរ ពួកព្រាហ្មណ៍បុរោហិត ជាអ្នកត្រួតពិនិត្យកិច្ចការមហាក្សត្រ ឬដឹកនាំរដ្ឋបាលជាន់ខ្ពស់ផ្ទាល់តែម្តង ដើម្បីឲ្យសមស្រប និង គោលការណ៍ធម៌ច្បាប់របស់ប្រទេស ។

ជាបឋម មហាក្សត្រខ្លួនឯង ត្រូវមានចំណេះវិជ្ជាគ្រប់វិស័យ និង មានសីលធម៌ យ៉ាងប្រាកដប្រជា និង ជ្រៅជ្រះណាស់ ពីព្រោះ "ព្រះអង្គដែលជាអម្ចាស់លើផែនដី ត្រូវបានជាព្រះគ្រូ នៃ មនុស្សលោកទាំងអស់"។ សិលាចារឹក នៅអង្គរ មានលើកជាអាទិ៍ថា ព្រះបាទយសោវរ្ម័ន ទី១, ព្រះបាទជ័យវរ្ម័ន ទី៥, ព្រះបាទសុរិយាវរ្ម័ន ទី១, ព្រះបាទឧទ័យទិត្យាវរ្ម័ន ទី២ ឬ ព្រះបាទជ័យវរ្ម័ន ទី៧ សុទ្ធតែជាមហាក្សត្រ មានចំណេះវិជ្ជាជ្រៅជ្រះណាស់ អំពីអក្សរសាស្ត្រ វេយ្យាករណ៍ ទស្សនវិជ្ជា ច្បាប់ វិទ្យាសាស្ត្រ... និងសិល្បសាស្ត្រ ឬបច្ចេកទេសផ្សេងៗទៀត ។ មហាក្សត្រ ទាំងនេះ ក៏មានព្រះហឫទ័យសប្បុរសណាស់ និង មានការអាណិតអាសូរយ៉ាងធំធេង ចំពោះជនក្រីក្រទុគ៌ត - *គឺដូចជាឪពុកសម្លាញ់របស់កូនទាំងអស់គ្នា ព្រះអង្គ ព្រះបាទជ័យវរ្ម័ន ទី៥ តែងតែជូតទឹកភ្នែកនៃប្រជារាស្ត្រ ដោយហត្ថាដ៏វែងរបស់ព្រះអង្គ* ។ គុណសម្បត្តិសំខាន់បំផុតទី៣ នៃ មហាក្សត្រខ្មែរ គឺសេចក្តីក្លាហានដ៏មោះមុត ក្នុងកិច្ចការពារអត្ថប្រយោជន៍របស់ប្រជារាស្ត្រ និង ប្រទេសជាតិ ។ នៅក្នុងរាជ្យព្រះបាទ-

សុរិយាវង្ស ទី ១ *"ទោះជាមនុស្សដេកលក់ នៅក្នុងព្រៃម្នាក់ឯង ក៏មិនមានការព្រួយបារម្ភ ក្រែងចោរមកលួចទ្រព្យសម្បត្តិរបស់ខ្លួនដែរ"* ។

នៅក្នុងលទ្ធិសាសនា នៃ សម័យក្រោយអង្គរ ចំពោះចំណេះក្នុងវិទ្យាសាស្ត្រ បច្ចេកទេសធំៗ និង សិល្បសាស្ត្រផ្សេងៗ ស្ទើរតែទាំងអស់ បានសាបរលាប ឬត្រូវគេបោះបង់ចោល ។ ព្រះសង្ឃពុទ្ធសាសនា នាពេលនោះ ហាក់ដូចជាបិទទ្វារ បង្អួចរបស់ខ្លួនជិតស្លុង លែងមានទំនាក់ទំនងជាមួយវដ្តបរទេសណាទាំងអស់ ។ ព្រះសង្ឃពុទ្ធសាសនា មិនត្រួតកិច្ចការមហាក្សត្រ និង មិនដឹកនាំរដ្ឋបាលជាតិផ្សេងៗទេ ហើយគ្រាន់តែធ្វើកិច្ចទូន្មាន ឲ្យមហាក្សត្រពិចារណា តាមគោលការណ៍សីលធម៌ សុទ្ធសាធនៃក្បួន "ទសពិធរាជធម៌" ។ ប៉ុន្តែ ច្បាប់ត្រីនេតិ បានកំណត់ល្អិតល្អន់ អំពីគុណសម្បត្តិចាំបាច់ នៃ មហាក្សត្រ និង នាម៉ឺនមុខមន្ត្រី ៖

*បពិត្រមហារាជ ទ្រើសទ្រង់អំណាច អញ្ជើញស្ដេចស្ដាប់ ទំនឹមទំនង នេះហោងជាច្បាប់ ទុកជាសណ្ដាប់ នៃនរជនជាតិ ។*

*នរអ្នកណា នឹងចូលទៅជា វររាជអាមាត្យ សេនាមន្ត្រី ករីជាអាទិ៍ រៀនច្បាប់ជាខ្នាត តែងទុករៀងទៅ ។ (ច្បាប់ត្រីនេតិ)*

នៅទីបំផុត ក្នុងករណីដែលមហាក្សត្រមិនគោរពចំពោះច្បាប់រដ្ឋ និងករណីយកិច្ចចាំបាច់ខាងលើនេះ អ្នកប្រាជ្ញខ្មែរយល់ថា ការរិះគន់ និងការបះបោរនៃប្រជាជន ជាការត្រឹមត្រូវ ៖

*ជាក្សត្រយ៍ពុំរៀនធម៌ ពុំដោះសាជម្ងឺឡូង រាស្ត្រទាសនឹងចំកោង*

*អាក់ចិត្តខឹងសត្វចោមរោម ។*

*-នឹងកើតក្តៅក្រហាយ ទុក្ខអន្តរាយភពផ្ទៃក្រោម រាស្ត្រផងនឹងខឹងចោម ជ្រោមខ្លាត់ខ្លាយទីទៃណា ។ (ច្បាប់វិធូរបណ្ឌិត)*

## សេចក្តីបញ្ចប់ "ខ្មែរអ្នកជា"

កូនខ្មែរគ្រប់សម័យ តែងតែប្រកាន់ប្រពៃណីរបស់ជាតិខ្លួនណាស់ ទោះបីមានការប្រែប្រួលក្នុងស្រុកខ្លួនម្តេចក្តី ពីព្រោះគេមានជំនឿយ៉ាងជ្រៅលើផលល្អនៃប្រពៃណីនោះ ។ ប្រជាជនខ្មែរមានជំនឿថា ធម៌-ច្បាប់ ប្រពៃណី និង ការចេះដឹង ជាកិច្ចធានាឲ្យមានសន្តិភាពសង្គម និង ជាកត្តាសំខាន់ៗបំផុត បង្កបង្កើតសេចក្តីចំរើន និង ឥទ្ធិពលខ្មែរ ។ ម្យ៉ាងទៀត លំដាប់ថ្នាក់ក្នុងសង្គមខ្មែរ ឈរលើកំរិតនៃការពិសោធន៍ របស់បុគ្គលម្នាក់ៗ គឺលើអាយុ លើកំពស់សីលធម៌ ឬលើសមត្ថភាពជាវិជ្ជមាន របស់បុគ្គលម្នាក់ៗ ។ ហេតុនេះ នៅក្នុងវិស័យនយោបាយ ខ្មែរតែងយល់ថា គេត្រូវប្រគល់អំណាច ទៅឲ្យបុគ្គលដែលចេះដឹងច្បាស់ អំពីធម៌-ច្បាប់ ហើយប្រតិបត្តិធម៌-ច្បាប់ គឺថា ជាព្រះបាទធម្មិក ។

ប្រពៃណីខ្មែរ មិនកើតមកពីទ្រឹស្តីសាសនាណាមួយទាំងស្រុងទេ ។ គឺជាគោលការណ៍ ដែលកើតមកពីការពិសោធន៍ ក្នុងជីវភាពជាក់ស្តែង ចំនួនរាប់ពាន់ឬរាប់ម៉ឺនឆ្នាំរបស់ប្រជាជនខ្មែរ ការពិសោធន៍ធំបំផុតរបស់ប្រជាជនខ្មែរ គឺសង្គ្រាមរាប់ពាន់ឆ្នាំ ដែលបានកើតឡើង ពីក្រៅស្រុកមកផង និងនៅក្នុងស្រុកខ្លួនផង ។ ជាច្រើនពាន់ឆ្នាំមកហើយ ទ្វីបអាស៊ី ជាទ្វីប

ដែលស្គាល់អំពើឃោរឃៅ និង សង្គ្រាម ឥតមានស្រាកស្រាន្តយូរទេ តាំងពីប្រទេសឥណ្ឌា ដល់ប្រទេសចិន និង តាមកោះធំៗ នៃ សមុទ្រជិតខាង ។ ហេតុនេះ ជាច្រើនពាន់ឆ្នាំមកហើយ ស្រុកខ្មែរ មិនមែនរស់ជា "កោះ-សន្តិភាព"ទេ ហើយការស្វែងរកឯកភាពជាតិ ដើម្បីបំបាត់សង្គ្រាមផ្ទៃក្នុង និងផ្តុំកម្លាំងជាតិ ជំនះសត្រូវពីក្រៅ ជាគោលដៅទីមួយ នៃ ការអប់រំជាប្រពៃណី របស់ប្រជាជនខ្មែរ ។ គេយល់ទៀតថា ឯកភាពជាតិនឹងកើតមាន លុះត្រាតែកូនខ្មែរ ចេះគោរពគ្នា ទើបស្រឡាញ់គ្នាបាន, ចេះស្រឡាញ់ ទើបចង់ជួយថែរក្សាគ្នា ជួយបណ្តុះបណ្តាលគ្នា (នេះគឺសាមគ្គីភាព), ចេះសាមគ្គីគ្នា ទើបតទល់នឹងសត្រូវបរទេស ដល់មានជោគជ័យបាន ។

ប្រពៃណី នៃ ការប្រយុទ្ធតស៊ូ នៃប្រជាជនខ្មែរ គឺការជំរុញកូនខ្មែរឲ្យមានទស្សនៈវែងឆ្ងាយ និងឲ្យមានមហិច្ឆតាធំធេង សម្រាប់ជាតិនិងមាតុប្រទេស របស់ខ្លួន ។ ខ្មែរមានពូជ ដែលជាពួកមានភាពថ្លៃថ្នូរ សុទ្ធសឹងជាអ្នកប្រកាន់សេរីភាពខ្លួនណាស់ គឺគេជា "ខ្មែរអ្នកជា" ហើយគេមិនអាចដាក់ខ្លួន ជាមនុស្សខ្ញុំគេឡើយ ៕

វត្តពោធិវង្ស ប្រទេសបារាំង ថ្ងៃទី ២៦ មេសា ឆ្នាំ ២០០៩

**ឌី ការ៉េត**

សូមគោរព អង្គប្រជុំ

សូមចំរើនពរ លោកស្រី លោកប្រុស និង ពុទ្ធបរិស័ទ

ទាំងឡាយ ។

វេលានេះ យើងកំពុងនាំគ្នាធ្វើសិក្ខាសាលាមួយ ប្រធានបទ **ខ្មែរមានពូជ** ។

ខ្មែរមានពូជ គឺខ្មែរយើងមានពូជល្អៗ មិនចាញ់ជាតិគេដទៃទេ ។ ខ្មែរយើងមានចំណេះវិជ្ជា មានចរិយាមារយាទ មានប្រពៃណី ទំនៀមទម្លាប់វប្បធម៌ល្អៗ មុនគេឯទៀតទាំងអស់ក្នុងអាស៊ីអាគ្នេយ៍នេះ ។ វាគ្មិន ៣នាក់ សុទ្ធតែថ្នាក់បណ្ឌិត លោកបានលើកយកនូវពូជល្អៗ របស់ខ្មែរយើងជាច្រើន មកជម្រាបជាភស្តុតាងស្រាប់ហើយ ។ អាត្មា សូមអនុមោទនាផង ។ ឥឡូវដល់វេនអាត្មាហើយ នៅចុងក្រោយគេបំផុត អាត្មាអ្នកបួស អ្នកសាសនា អ្នកធម៌អាថ៌ ដូចនេះ សូមជម្រាបផ្នែក សាសនាខ្លះៗ ដូចតទៅនេះ ៖

១-**ពូជខ្មែរអ្នកប្រាជ្ញ** ខ្មែរយើងមានអ្នកប្រាជ្ញ សូម្បីតែខាងសាសនាក៏មានអ្នកប្រាជ្ញ តាំងពីសម័យនគរភ្នំមក ។ ក្នុងរជ្ជកាលព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ន មានព្រះសង្ឃអ្នកប្រាជ្ញខ្មែរ២អង្គ គឺព្រះសង្ឃបាល និងព្រះមន្ទ្រសេន បាននិមន្តទៅជួយប្រែគម្ពីរពុទ្ធសាសនា មានគម្ពីរវិមុត្តិមគ្គជាដើម នៅប្រទេសចិន ។ (ពេលនោះ ប្រទេសជិតខាងយើង គេមិនទាន់ចូលមកនៅទឹកដីសព្វថ្ងៃនេះទេ លុះពេលគេចូលមក គេនៅអាស្រ័យ

ទឹកដីយើង វប្បធម៌យើង ព្រោះគេមិនសូវមានវប្បធម៌ទេ) ។ សេចក្ដីប្រែជាស្នាព្រះហស្តរបស់ព្រះសង្ឃខ្មែរទាំង ២ ព្រះអង្គនោះ កាលពីឆ្នាំ ១៩៥៦ សម្ដេចសីហនុ យាងទៅប្រទេសចិន គេបានយកមកថ្វាយទត ទុកជាមិត្តភាពខ្មែរ ចិន ផង ។ ខ្មែរត្រូវតែរក្សាទុកនូវពូជអ្នកប្រាជ្ញ គឺត្រូវខំសិក្សារៀនសូត្រឲ្យចេះដឹងច្បាស់លាស់ពិតប្រាកដ មានកំរិតខ្ពស់ អាចទៅជាអ្នកប្រាជ្ញអន្តរជាតិបាន ។

២-**ពូជខ្មែរនគរវត្ត** ព្រះបាទសូរិយាវរ្ម័ន ទី ២ បានសាងប្រាសាទនគរវត្ត បង្កប់ទុកនូវអត្ថន័យជ្រាលជ្រៅណាស់ ។ នគរ មានអត្ថន័យថា នគរ ឬ ជាតិ, វត្ត មានអត្ថន័យថា វត្ត ឬ សាសនា ។ ជាតិ និង សាសនា អាណាចក្រ និង សាសនចក្រ (ពុទ្ធចក្រ) ត្រូវទៅជាមួយគ្នា រួមគ្នាគិតដោះស្រាយកសាង ការពារ ជាតិ សាសនា មិនមែនដាច់គ្នាស្រឡះ គិតតែប្រយោជន៍ផ្នែកខ្លួន មិនគិតប្រយោជន៍ផ្នែកដទៃនោះទេ ប៉ុន្តែ ត្រូវគិតឲ្យជាតិ រស់ និង ចំរើនរុងរឿងមុន ហើយសឹមជួយសាសនាឲ្យរស់ និង រុងរឿងបន្ទាប់ជាមួយគ្នាផងដែរ ។ ពូជខ្មែរនគរវត្តនេះជ្រៅណាស់ សំខាន់ណាស់ កូនខ្មែរត្រូវតែយល់ និង បដិបត្តិឲ្យបាន ។

៣-**ពូជខ្មែរព្រហ្មាយ័ន** ព្រះបាទជ័យវរ្ម័ន ទី ៧ បានសាងប្រាសាទព្រហ្មាយ័ន ដែលមានសិរសាព្រះព្រហ្មជាកំពូល ។ បានសេចក្ដីថា ខ្មែរត្រូវតែយកព្រហ្មវិហារធម៌៤ គឺ មេត្តា ករុណា មុទិតា ឧបេក្ខា ជាកំពូលជាមាគ៌ា សំរាប់អនុវត្ត ចាប់ផ្ដើមពីអ្នកដឹកនាំគ្រប់ជាន់ថ្នាក់ ត្រូវតែមានព្រហ្មវិហារធម៌ សូម្បីតែប្រជាជន ក៏ត្រូវមានព្រហ្មវិហារធម៌ រវាងគ្នា

និងគ្នា ដែរ ។ ព្រះបាទជ័យវរ្ម័ន ទី ៧ មានព្រះហឫទ័យ អាណិតអាសូរ ប្រជានុរាស្ត្រខ្លាំងណាស់ ទុក្ខរបស់រាស្ត្រ គឺជាទុក្ខរបស់ព្រះអង្គ... ។ សូម្បីតែសត្វ ក៏ព្រះអង្គ អាណិតអាសូរដែរ មានរហូតដល់សាងមន្ទីរពេទ្យ ព្យាបាលរោគសត្វទៀតផង ។ ព្រះអង្គតាំងព្រះទ័យ នឹងសាងប្រទេសខ្មែរ ឲ្យទៅជា ស្ថានសួគ៌ សាងប្រជាជនខ្មែរឲ្យទៅជា ទេវតា... ។ មិនមែន គិតរត់ចោលស្រុកមនុស្សទៅរកស្រុកទេវតា ដូចបុគ្គលខ្លះកាន់សាសនា ជ្រុលហួសនោះទេ ។ ពូជខ្មែរព្រហ្មបាយ័ន កូនខ្មែរត្រូវតែយកព្រហ្មវិហារ ធម៌ មកបដិបត្តិក្នុងជីវិតប្រចាំថ្ងៃវិញឲ្យបាន ។

៤-**ពូជខ្មែរព្រះខាន់** ព្រះបាទជ័យវរ្ម័ន ទី ៧ បានសាងប្រាសាទព្រះ ខាន់ មិនមែនក្នុងគោលបំណង សាងព្រះខាន់ ឬ តម្កល់ទុកនូវព្រះខាន់ ជារូបធាតុ(ដែក)នោះទេ ។ សេចក្ដីពិត ព្រះអង្គ ចង់សាងព្រះខាន់ផ្លូវ ធម៌ គឺបញ្ញាភ្លឺស្វាង ដឹងខុស ដឹងត្រូវ ដឹងខាត ដឹងចំណេញ... ចេះ គ្រប់គ្រងខ្លួន ចេះកាត់ផ្ដាច់កិលេសគឺឈ្នះនូវអំពើអាក្រក់របស់ខ្លួនជាដើម ។ បុគ្គលដែលមានបញ្ញាជាព្រះខាន់បែបនេះ ទើបអាចសាងសេចក្ដីសុខដល់ ខ្លួន ដល់អ្នកដទៃ និង ដល់ប្រទេសជាតិបាន ។ អាស្រ័យហេតុនេះ ទើប ព្រះអង្គ ហ្វឹកហាត់មនុស្ស ពិសេសអ្នកដឹកនាំប្រជាជន ឲ្យគេនាំគ្នាបដិបត្តិ សមាធិ (សីល សមាធិ បញ្ញា) ដើម្បីយកសេចក្ដីសុខ ចំរើន តាំង ពីក្នុងជីវិតបច្ចុប្បន្ននេះទៅ មិនមែនរំលងចោល នូវប្រយោជន៍ក្នុងជាតិ នេះ ហើយចាំទទួលផលប្រយោជន៍ក្នុងស្ថានសួគ៌ ឬ ព្រះនិព្វាន នោះ ទេ ។ នេះហើយជាពូជខ្មែរព្រះខាន់ ជាពូជដ៏ប្រសើរវិសេស ដែលកូនខ្មែរ

គ្រប់គ្នាត្រូវតែមានបញ្ញា កុំចង់រស់តែឯង... កុំចាញ់បោកបរទេស ។

៥-**ពូជខ្មែរអ្នកបួស** តាមប្រវត្តិសាស្ត្រ តំណាលថា ព្រះបាទអសោក មហារាជ ព្រះអង្គ ជាកំពូលអគ្គពុទ្ធសាសនូបត្ថម្ភក៏ ក្នុងជម្ពូទ្វីប ។ ព្រះអង្គ ត្រាស់សួរថា ព្រះអង្គ បានទំនុកបំរុងពុទ្ធសាសនាច្រើនយ៉ាងនេះ តើបានជាញាតិក្នុងពុទ្ធសាសនាហើយឬនៅ ? ព្រះមោគ្គល្លីបុត្ត តិស្សត្ថេរ ថ្វាយព្រះពរថា ព្រះអង្គ មិនទាន់បានជាញាតិទេ ព្រោះព្រះអង្គ មិនទាន់បានទ្រង់ព្រះផ្នួស ឬ មិនទាន់បានបំបួសព្រះរាជបុត្រា បុត្រីនៅឡើយ ។ អាស្រ័យហេតុនេះ ទើបព្រះបាទអសោក ទ្រង់បំបួសព្រះរាជបុត្រ គឺ ព្រះមហិន្ទ និង ព្រះរាជបុត្រី គឺ ព្រះសង្ឃមិត្តា ដែលក្រោយមក បានជាសមណទូត ទៅប្រកាសពុទ្ធសាសនា នៅប្រទេសសិរីលង្កា ជាភស្តុតាងស្រាប់ ។

ខ្មែរយើងចាប់តាំងពីកាន់ពុទ្ធសាសនាមក ក៏បានអនុវត្តតាមប្រពៃណីនេះ តាំងពីសម័យនគរភ្នំរៀងរហូតមក ។ នៅប្រាសាទនគរវត្ត ថ្នាក់កណ្ដាល ក៏មានចារឹករឿង ព្រះមហាក្សត្របំបួសព្រះរាជបុត្រនេះដែរ ។ ប៉ុន្តែ ចាប់តាំងពីសម័យបារាំងចូលគ្រប់គ្រងប្រទេសកម្ពុជាមក ខ្មែរយើងចាប់សាបរលាបរឿងបួសនេះរឿយ ។ រហូតមក ។ ឥឡូវ យើងត្រូវតែបដិបត្តិឲ្យបានល្អឡើងវិញ ។

ពូជខ្មែរអ្នកបួស មិនមែនបួសគ្រាន់តែរៀនចំណេះវិជ្ជា មានអក្សរសាស្ត្រ ជាដើមនោះទេ គោលបំណងសំខាន់ គឺបួសដើម្បីអប់រំកាយ វាចា ចិត្ត ឲ្យល្អ ឲ្យដឹងខុស ត្រូវ អ្វី គួរធ្វើ អ្វី មិនគួរធ្វើជាដើម ។

អ្នកបួស គេទុកជាអ្នកបានអប់រំហើយ បើសឹកមកវិញ គេហៅថា បណ្ឌិត (អន្និត) បើគេត្រូវការស្តីដណ្តឹងប្រពន្ធ ក៏មិនជាការពិបាកអ្វីពេកទេ ។ ចំណែក អ្នកមិនបានបួស ប្រៀបដូចគោ មិនបានពង្រាប ប្រើការមិនកើត គេហៅថា អា មឹង រហូត បើគេត្រូវការស្តីដណ្តឹងប្រពន្ធ មិនសូវមាននរណាចង់ឲ្យកូនចៅទេ ។ ពូជខ្មែរអ្នកបួស ជាពូជល្អ ខ្មែរយើងត្រូវតែរក្សាពូជនេះ តទៅទៀត ។

លោកស្រី លោកប្រុស បងប្អូនខ្មែរទាំងឡាយ ពូជខ្មែរយើងល្អណាស់ តើយើងគិតយ៉ាងម៉េច ? យើងត្រូវរក្សាពូជយើង ជាតិយើងយ៉ាងម៉េច ? យើងជាកូនល្អរបស់ខ្មែរហើយឬនៅ ? យើងត្រូវលះបង់អ្វីខ្លះ ? យើងត្រូវធ្វើអ្វីខ្លះ ? ដើម្បីរក្សា ការពារ លើកតម្កើងពូជរបស់ខ្មែរយើង ឲ្យបានថ្កុំថ្កើងរុងរឿងឡើងវិញ ។ សូមក្រោកឡើង សូមរួមគ្នាកសាង ការពារ លើកតម្កើងពូជខ្មែរ ជាតិខ្មែរយើង ជាប្រញាប់ ៕

សូមចំរើនពរ

ភិក្ខុ ងិន ភេន ឥន្ទបញ្ញោ

# ភាគសំណួរ និង ចម្លើយ

<u>សំណួរ - (លោក អាន តាំងគីម)</u> ខ្មែរមានពូជល្អ ប៉ុន្តែ យើងសង្កេតឃើញថា ស្រុកខ្មែរចេះតែធ្លាក់ចុះហិនហោចជាខ្លាំងបន្តបន្ទាប់គ្នា... តើពូជល្អរបស់ខ្មែរ មានគ្រប់គ្រាន់ឬទេ ?

<u>ចម្លើយ - (ភិក្ខុ ងិន ភេន)</u> យើងមានពូជល្អច្រើនណាស់ មិនចាញ់ជាតិដទៃទេ គួរឲ្យយើងមានមោទនភាព ។ ប៉ុន្តែ ការកសាងខ្លួន (ឬជាតិ) យើងត្រូវទុកដាក់ខ្លួន ដូចកែវទឹកដែលមិនពេញ អាចទទួលទឹកថែមទៀតបានជានិច្ច ។ យើងត្រូវតែបន្ថែម គឺស្វែងរកចំណេះវិជ្ជា របៀបរបបសណ្តាប់ធ្នាប់ថ្មី ៗ ពីទីផ្សេង ៗ មកទៀត ឲ្យបានរឹតតែល្អ រឹតតែថ្លៃថ្នូរថែមទៀត កុំខ្ជិល កុំជោរ កុំប្រមាទ ។

<u>ចម្លើយ - (លោក ឌី កាម៉េត)</u> ការធ្លាក់ដុនដាបរបស់ខ្មែរ បានកើតមានតាំងពីចុងសម័យអង្គរមកម្ល៉េះ ។ ខ្មែរបានធ្លាក់ដុនដាប ព្រោះខ្មែរ (ជាពិសេស គឺអ្នកដឹកនាំ) បានបោះបង់នូវការអប់រំល្អរបស់ជាតិសាសន៍ខ្លួន ។ គេផ្តើមលែងគោរពធម៌ លែងគោរពច្បាប់ និង ប្រពៃណីល្អ ហើយនាំសង្គម-ជាតិ តាមអំពើចិត្តខ្លួន ជាហេតុបណ្តាលឲ្យប្រជាជនខ្លួន និងប្រទេសជាតិ ខូចបង់ប្រយោជន៍ បាត់បង់កម្លាំងខ្លួនទៅ ។ យើងត្រូវដឹងថា ការអប់រំខ្មែរ បានកើតមកជាពិសេស ពីការពិសោធន៍អំពីអសន្តិសុខ និង សង្គ្រាម ឥតឈប់ឈរ នៅជុំវិញខ្លួន ។ ហេតុនេះ ការអប់រំខ្មែរ សង្កត់ខ្លាំងឲ្យកូនខ្មែរចេះគោរពគ្នា ស្រឡាញ់គ្នា និង មានសាមគ្គី

ភាពជាមួយគ្នាយ៉ាងមាំមួន ទើបគេអាចទប់ទល់នឹងអំពើឃោរឃៅសង្គ្រាមបាន ហើយបានរស់ និង រុងរឿងទាំងអស់គ្នា បានយូរអង្វែង ។

<u>សំណួរ- (លោក ត្រានទុំ រ៉េមី)</u> យើងនិយាយថា ខ្មែរមានពូជល្អ ។ ខ្ញុំសុំសួរ- ទី ១- តើខ្មែរដែលសម្លាប់គ្នាអស់រាប់លាននាក់ វាជាប់ពូជមកពីហ្នឹងដែរឬ ? ទី ២- តើសៀម កើតពីពេលណាមក ? បុរាណវត្ថុសៀម និង បុរាណវត្ថុខ្មែរ ប្លែកគ្នាដូចម្ដេច ? ហេតុអ្វីបានជាសៀមហ៊ានទាមទារយកប្រាសាទព្រះវិហារ ?

<u>ចម្លើយ- (លោក ចាយ ស៊ីរុន្ធ)</u> រឿងខ្មែរសម្លាប់គ្នាឯង មិនមែនខុសមកពីខ្មែរមានពូជទេ វាខុសមកពីបុគ្គលខ្មែរមិនធ្វើតាមពូជល្អរបស់ខ្លួន... បែរជាអ្នកលោភលន់ ស្រវឹងបុណ្យ ឆ្កួតអំណាច ស្ដេចដណ្ដើមរាជ្យ នាម៉ឺនដណ្ដើមស័ក្តិយស មើលតែសព្វថ្ងៃនេះ ល្មមយល់បានហើយ ។

ចំពោះសៀម សៀមទើបនឹងកើតឡើងជារដ្ឋ នៅពាក់កណ្ដាលសតវត្សរ៍ទី ១៣ នេះឯង ។ សៀមមិនសូវមានវប្បធម៌ទេ គេរៀនសូត្រចំណេះវិជ្ជា និង ចម្លងវប្បធម៌ពីខ្មែរ ។ បុរាណវត្ថុសៀម ប្លែកពីខ្មែរ ដូចខ្ញុំបានជម្រាបខាងដើមស្រាប់ហើយ ។ ឯប្រាសាទព្រះវិហារ ជាសម្បត្តិរបស់ខ្មែរ តាំងពីដើមមក ប៉ុន្តែ សៀមចេះតែឈ្លានពានដណ្ដើមយក ។ ពីឆ្នាំ ១៩៦២ តុលាការក្រុងឡាអេ បានកាត់សេចក្ដីសម្រេចម្ដងទៀត ថាប្រាសាទព្រះវិហារជាសម្បត្តិរបស់ខ្មែរ ត្រឹមត្រូវតាមច្បាប់ ពិតប្រាកដហើយ ។ តែសព្វថ្ងៃនេះ សៀមនៅតែឈ្លានពានឥតអៀនខ្មាស ដណ្ដើម

យកប្រាសាទព្រះវិហាររបស់ខ្មែរដូចលើកមុនដដែល ។

<u>ចម្លើយ (ភិក្ខុ ធិន ភេន )</u> សៀមតែងនិយាយថា ខ្មែរ(ខម) អ្នកសាងអង្គរងាប់អស់ហើយ ខ្មែរសព្វថ្ងៃនេះ មិនមែនជាប់ពូជខ្មែរអ្នកសាងអង្គរទេ គឺជាខ្មែរថ្មី ។ នេះ ជាគំនិតអាក្រក់របស់សៀម ដែលគេចង់បន្លំយកទឹកដីរបស់ខ្មែរ ចង់បំភ្លេចគុណរបស់ខ្មែរ និង មិនចង់ឲ្យមានពូជខ្មែរធ្លាប់ពូកែជាងពួកគេរស់នៅទេ ។

យើងកុំចាញ់បោកគេ ។ យើងគិតមើល ខ្មែរច្បាំងជាមួយសៀមរហូត ម៉េចក៏ងាប់អស់ផុតពូជ ? បានពូជថ្មីមកពីណាភ្ជាមពេញទឹកដីខ្មែរនេះ ? ពូជខ្មែរអង្គរមិនងាប់អស់ផុតពូជទេ អាត្មា ជឿថា អាត្មាហ្នឹងមួយនាក់ហើយ ជាប់ពូជមកពីខ្មែរអង្គរ លោក អ្នក ទាំងអស់គ្នាហ្នឹង ក៏ជាប់ពូជអង្គរដូចគ្នា ដែរ ។

ជាធម្មតា ពូជផ្កា ពូជស្រូវ អាចក្លាយបាន ពូជមនុស្ស (ខ្មែរ) ក៏អាចក្លាយបានខ្លះដូចគ្នាដែរ ។ ពួកអ្នកក្លាយៗហ្នឹង ច្រើនមិនដឹងថាពូជរបស់ខ្លួនល្អ ហើយបង្កទោសដល់ពូជរបស់ខ្លួនវិញ ។ ហេតុនេះយើងត្រូវថែរក្សា ត្រូវអប់រំ និង ឧស្សាហ៍ជ្រើសរើសពូជដូចស្រូវដូចនោះ ។

អ្នកជាប់ពូជមកពីសម័យអង្គរក្តី អ្នកចូលមកក្រោយក្តី នរណាស្រឡាញ់ទឹកដីកម្ពុជា ស្រឡាញ់វប្បធម៌ខ្មែរ ហើយថែរក្សា ការពារដោយទឹកចិត្តស្មោះត្រង់ពិតប្រាកដ នរនោះ សុទ្ធតែជាជាតិខ្មែរទាំងអស់ ។ យើងត្រូវតែស្រឡាញ់រាប់អានគ្នា រួបរួមសាមគ្គីគ្នា ជាធ្លុងមួយ រៀងរហូត។

ចម្លើយ (លោក ឌី ការ៉េត) ការអប់រំរបស់ខ្មែរ មិនដែលបិទទ្វារ-បិទបង្អួចខ្លួនទេ គឺតែងតែទទួលចំណេះវិជ្ជា ពីខាងក្រៅមក ឲ្យតែចំណេះវិជ្ជានោះ មកផ្តល់សេចក្តីចំរើន សមតាមចិត្តខ្មែរចង់បាន ។

ចម្លើយ (លោក ស៊ុយ ស៊ាងហេង) -ខ្ញុំសុំលើកឧទាហរណ៍ថា បើទោះជាយើងមានរថយន្តល្អប្រើហើយ តែបើយើងមិនបើកបរតាមច្បាប់ចរាចរ ឬ មួយក៏តាមផ្លូវថ្នល់វាមិនបាក់បែក នោះ យើងបើករថយន្តទៅនឹងមានគ្រោះថ្នាក់ អាចស្លាប់ទាំងខ្លួនផង ។

សេចក្តីអធិប្បាយរបស់លោក ថាច់ វៀន - ជនជាតិខ្មែរ ពិតជាមានឫសគល់នៅប្រទេសឥណ្ឌាមែន ហើយបាននាំគ្នាចុះមកនៅទីកន្លែងសព្វថ្ងៃ តាំងពី ៤ ឬ ៥ ពាន់ឆ្នាំមកហើយ ។ កាលពីឆ្នាំ ១៩៩៨ នៅអង្គការសហប្រជាជាតិ ខ្ញុំបានជួបភូមាមួយក្រុម ដែលនៅកណ្តាលស្រុកភូមា ។ ពួកនេះ បានប្រាប់ខ្ញុំថា គេជាជនជាតិខ្មែរ តាំងពីយូរយារណាស់មកហើយ ហើយគេចេះភាសា និង អក្សរខ្មែរជានិច្ច គ្រាន់តែអានតាមសម្លេងបាលី ខុសពីខ្មែរសព្វថ្ងៃនេះបន្តិចប៉ុណ្ណោះ គឺគេថា កះ ខះ គះ ឃះ ងះ មិនថា ក ខ គ ឃ ង ដូចយើងទេ ។ នេះបង្ហាញថា យើងបានកាន់កាប់ទឹកដី ខ្មែរលើ ខ្មែរកណ្តាល ខ្មែរក្រោម ជាច្រើនពាន់ឆ្នាំមកហើយ ។ ប៉ុន្តែ សព្វថ្ងៃនេះ ពួកអាជ្ញាធរវៀតណាម គេខំកែប្រែប្រវត្តិសាស្ត្រថា ខ្មែរនៅកម្ពុជាក្រោម គឺជាអ្នកមកសុំជ្រកកោននៅស្រុកយួនខាងត្បូងទេ ដោយសារស្រុកខ្មែរមានសង្គ្រាម គឺថាខ្មែរយើងនោះ មិនមែនជាម្ចាស់ដើម នៃ

កម្ពុជាក្រោមទេ ។ យើងមិនត្រូវចាញ់បោកគេទេ ។

ខ្ញុំយល់ថា ការអប់រំអំពីពូជសាសន៍ខ្មែរ មានសារៈសំខាន់ណាស់ ។ ខ្ញុំនៅចាំច្បាស់ថា កាលពីឆ្នាំ ១៩៥៦ នៅវិទ្យាល័យ ស៊ីសុវត្ថិ គេឥត បង្រៀនកូនខ្មែរ អំពីវិជ្ជាពលរដ្ឋទេ គឺវិជ្ជាឲ្យខ្មែរដឹងស្គាល់នូវករណីកិច្ច និងសិទ្ធិ របស់ខ្លួន ឲ្យស្គាល់ជាតិសាសន៍ខ្លួន និង ពូជពង្សខ្លួន ។ រដ្ឋមាន ភារកិច្ចធំណាស់ ក្នុងការអប់រំប្រជាជន ឲ្យចេះដឹង និង អនុវត្តបានល្អ នូវ រឿងនេះ ។ ខ្ញុំយល់ឃើញថា ខ្មែរយើងទោះបីគេនៅទីកន្លែងណាក៏ដោយ យើងមិនគប្បីប្រមាថមើលងាយគ្នាទេ យើងត្រូវតែស្រឡាញ់រាប់អានគ្នា រួបរួមសាមគ្គីគ្នា ជាដរាប ។

<u>សំណួរ (លោក ទិត ហួន)</u> - ជាបឋម ខ្ញុំសូមជម្រាបថា ខ្ញុំ ជាសាក្សីម្នាក់ ជាខ្មែរមានជាតិ ហេមោគ្លោប៊ីន អ៊ី ព្រោះពេទ្យបារាំង បានរកឃើញនៅក្នុងឈាមខ្ញុំ នូវជាតិហ្នឹងតែម្តង ។ សំណួររបស់ខ្ញុំ គឺ យើង និយាយថា ខ្មែរមានពូជល្អ ប៉ុន្តែ គេថា ខ្មែរអង្គុយមើលស្រូវដុះ គេថា ខ្មែរខ្ជិល មិនចេះធ្វើការអ្វី ដូចជាងធ្វើផ្ទះ ធ្វើភ្លើង ។ល។ សូម្បីតែកាត់វះត្រី ឃើញតែយួនធ្វើ...តើពាក្យហ្នឹងពិត ឬគេបង្អាប់យើង ?

<u>ចម្លើយ (លោក ចាយ សិរីវុឌ្ឍ)</u> - ខ្ញុំសប្បាយចិត្តណាស់ ដោយបានលោកជាសាក្សីម្នាក់ មានជាតិ ហេមោគ្លោប៊ីន អ៊ី ។ ក្នុងរឿង ការងារនៅប្រទេសបារាំង គេខំកែទម្រង់សាលារៀនច្រើនណាស់ ដោយ គេចង់ឲ្យមានការសិក្សាចំណេះវិជ្ជា ជាអចិន្ត្រៃយ៍ ដល់មនុស្សគ្រប់គ្នា

ដើម្បីអាចប្រកបការងារបានតាម កាលៈ ទេសៈ ជានិច្ច ។ បើខ្មែរខ្ជិល ពីព្រោះតែអ្នកដឹកនាំអប់រំជាតិខ្មែរ មិនបានរៀបចំឲ្យពលរដ្ឋចេះដឹងក្នុង ការងារផ្សេងៗ ទាំងនោះ វាមិនមែនខុសមកពីពូជខ្មែរទេ ។

ចម្លើយ (លោក ស៊ុយ ស៊ាងហេង) ខ្ញុំសូមបញ្ជាក់តាមពាក្យ បរទេសគេថា - (ឡាវដេកស្តាប់ស្រូវដុះ ខ្មែរអង្គុយមើលស្រូវដុះ វៀតណាម ថែរក្សាស្រូវដុះ) ។

ចម្លើយ - (លោក ឌី កាវ៉េត) មនុស្សខ្ជិលធ្វើការអ្វីមួយ ច្រើន ជាមនុស្សដែលល្ងង់ខ្លៅ ឬក៏ គ្មានសង្ឃឹមលើការងារនោះ ។ ជាច្រើនរយ ឆ្នាំហើយ ដែលសេដ្ឋកិច្ចស្រុកខ្មែរ បានធ្លាក់ក្នុងកណ្តាប់ដៃបរទេសទាំង ស្រុង គឺ ចិន យួន បារាំង ។ល។ សមាគមបរទេសនេះ មានបណ្តាញ សេដ្ឋកិច្ចរបស់គេ នៅពាសពេញស្រុកខ្មែរ ហើយការពារបណ្តាញគេ មិន ឲ្យខ្មែរចូលចុះ អាចឈរជើងនៅផ្សារធំៗនៃការងារពាណិជ្ជកម្ម ឬ ឧស្សាហ កម្ម ។ ខ្មែរយើងមានការងារតែក្នុងស្រែចំការ និង ទូលកញ្ជើដើរលក់ដូរ បន្តិចបន្តួច ។ តូប ឬ ហាងធំៗ ត្រូវបាន ចិន យួន កាន់កាប់ទាំង អស់ ។ កាលពីដើមសតវត្សរ៍មុន បារាំងចាត់ចែងធ្វើចំការកៅស៊ូ ដើម្បី យកជ័រនៅជប់ (កំពង់ចាម) តែគេយកយួនរាប់ពាន់នាក់ តាំងពីតុងកឹង មកធ្វើ ។ បើត្រឹមតែការងារប៉ុណ្ណឹង ហេតុអ្វីក៏ចាំទៅយកយួនមកធ្វើ តើ ខ្មែរមិនអាចចេះធ្វើឬអ្វី ? ។ ឧទាហរណ៍ថ្មីៗមួយទៀត នៅពេលយួនចូល កាន់កាប់កម្ពុជា ពីឆ្នាំ ១៩៧៩ ។ ពេលនោះ គេចាប់យុវជនខ្មែរ ឲ្យធ្វើ

ជាទាហានចេញទៅច្បាំង ប៉ុន្តែ គេនាំយុវជនយួនពីស្រុកយួន មកធ្វើជាជាងសង់ផ្ទះ ជាងធ្វើភ្លើង ជាងធ្វើម៉ាស៊ីន នៅគ្រប់កន្លែង ។ ហេតុនេះ បើខ្មែរមិនអាចចេះវិជ្ជាអ្វីៗនោះទេ ហើយមិនអាចកាន់កាប់ផ្សារសេដ្ឋកិច្ចរបស់ខ្លួនទៀត តើឲ្យខ្មែរមានសង្ឃឹមថា នឹងបានដុះដាលក្នុងការងារ ហើយចង់ប្រកបការងារទាំងនោះឬទេ ? ។

<u>ចម្លើយ - (ភិក្ខុ ងិន ភេន)</u> ព្រះពុទ្ធ សម្តែងថា បើគេប្រាប់កំហុស ដូចគេឲ្យកំណប់ទ្រព្យ កុំខឹង ត្រូវតែពិចារណាមើលឲ្យច្បាស់ ។ រឿងខ្ជិលធ្វើការងារ មិនមែនជារឿងខ្មែរមានពូជទេ ជារឿងរបស់បុគ្គល ជារឿងរបស់អ្នកល្ងង់ចង់ដឹកនាំ ចូរពិចារណាមើលខ្លួនឯងឲ្យច្បាស់ហើយដោះស្រាយ ។ កាលពីឆ្នាំ ១៩៨២ អាត្មា បានទៅខេត្តកំពង់ឆ្នាំង បានឃើញយួនរកស៊ីចាប់ត្រីជាច្រើននៅទន្លេសាប ។ ខ្មែរមិនសូវហ៊ានចូលទៅចាប់ត្រីទេ ព្រោះច្រើនមានគ្រោះថ្នាក់ ឬ បាត់ខ្លួន... ។ ចំពោះខ្មែរដែលចូលទៅសុំធ្វើជាកម្មករ ឆ្អើត្រី កាត់ក្បាលត្រី វះពោះត្រី ដែលអាចរកកម្រៃបាន ២០៛ក្នុង១ថ្ងៃ យួនមិនឲ្យខ្មែរធ្វើទេ វាទុកឲ្យយួនគ្នាវាធ្វើវិញ ។ បើខ្មែរចង់ធ្វើការ ត្រូវចុះទឹក រាវដោះសំណាញ់ ឬ ហាលសំណាញ់ ដែលគិតជាប្រាក់ខែ ៩០៛ ក្នុងខែតែប៉ុណ្ណោះ ។ នេះហើយ គេថា ខ្មែរគ្មានចេះធ្វើអ្វីទេ ខ្មែរមានត្រី តែខ្មែរមិនចេះឆ្អើត្រី... ។ អ្នកដឹកនាំ ត្រូវតែគិត និង ដោះស្រាយ ។

<u>សំណួរ (លោក ម៉ក់ សារ្ង)</u> - ស្នើសុំ លោក វេជ្ជបណ្ឌិត

ស៊ុយ ស៊ាងហេង ចេញវេជ្ជបញ្ញា ដើម្បីពិនិត្យមើលជាតិ ហេមោគ្លោប៊ីន អ៊ី ក្នុងឈាម ។

<u>ចម្លើយ (លោក ស៊ុយ ស៊ាងហេង)</u>-មិនចាំបាច់ទេ ហេមោគ្លោប៊ីន អ៊ី គេមិនទាន់រកឃើញ ថាមានលក្ខណៈយ៉ាងណាៗ នៅឡើយទេ ។

<u>សំណួរ (លោក ហាក់ ព្រួ)</u>- ខ្ញុំសប្បាយចិត្តណាស់ ដោយបានឃើញមានមនុស្សស្លាប់ច្រើនគ្រាន់បើ ប៉ុន្តែ ច្រើនតែចាស់ៗ តើទៅអនាគតទៅ គិតយ៉ាងម៉េចដែរ បើចាស់ៗចេះតែរលស់ចុះថយទៅៗ... ?

<u>ចម្លើយ (ភិក្ខុ ងិន ភេន)</u>- អាត្មាក៏ចាស់ណាស់ហើយដែរ នៅមិនបានយូរប៉ុន្មានទៀតទេ ។ ប៉ុន្តែ អាត្មា កំពុងតែគិត កំពុងតែធ្វើរាល់តែថ្ងៃ ធ្វើការអប់រំ សរសេរសៀវភៅ ធ្វើសិក្ខាសាលា ។ល។ ថ្មីៗនេះទើបនឹងបង្កើត សមាគមដូនជីខ្មែរមួយ ជួយសាមគ្គីគ្នាធ្វើការថែមទៀត ។ អាត្មា សូមអញ្ជើញ លោកប្រុស លោកស្រី បញ្ញវន្ត ចាស់ ក្មេង ទាំងឡាយ ចូលរួមសាមគ្គីគ្នាធ្វើកិច្ចការ ដើម្បីជាប្រយោជន៍ ជាតិ សាសនារបស់យើង ដោយមេត្រីភាព ។

សូមចំរើនពរ

<u>អ្នកដឹកនាំការប្រជុំ (ភិក្ខុ ពេជ្រ សាម៉ុន)</u> អាត្មា សូមថ្លែងអំណរគុណអស់លោក វាគ្មិន និង លោកប្រុស លោកស្រី ដែលបានចូលមករួមប្រជុំក្នុងសិក្ខាសាលានេះ យ៉ាងជ្រាលជ្រៅ សូមបានប្រកបដោយពុទ្ធពរទាំងឡាយ៤ប្រការ កុំបីឃ្លៀងឃ្លាតឡើយ ។ សូមបិទអង្គប្រជុំ ៕

# ប្រធានបទបន្ថែម

៙*៚

## ខ្មែរមានពូជល្អ តែធ្លាក់ខ្លួនដុនដាប

***

បន្ទាប់ពីកិច្ចប្រជុំមក ភ្ញៀវខ្លះបានលើកសំណួរមួយចំនួនថា ៖ បើខ្មែរមានពូជល្អ ចុះហេតុអ្វីបានជាខ្មែរធ្លាក់ខ្លួនដុនដាបដូចសព្វថ្ងៃ ? ហេតុអ្វីក៏ខ្មែរចោលវប្បធម៌របស់ខ្លួន ហើយរើសយកតែរបស់បរទេសមកវិញ ? ហេតុអ្វីក៏ខ្មែរលែងទុកចិត្តលើខ្លួនឯង និង លើគ្នីគ្នាឯង ? ។ល។ គេថាពួកយើងនិយាយអួត និយាយភ្លេចភ្នែក... ។

ចម្លើយ -

សិក្ខាសាលាពុំមានពេលគ្រប់គ្រាន់នឹងឆ្លើយចំពោះ សំនួរទាំងអស់នោះទេ ។ យើងបានពិគ្រោះគ្នាជាបន្ទាប់ ហើយជូនចម្លើយដូចតទៅ ។

តាមរយៈការសិក្សាប្រវត្តិសាស្ត្រ ការចុះដុនដាបរបស់ខ្មែរ បានកើតឡើងដោយសារសង្គ្រាមផ្ទៃក្នុង និង សង្គ្រាមបរទេសឥតឈប់ឈរ ចាប់ពីដើមសតវត្សទី ១៤ (សម័យអង្គរ) រហូតមកដល់កណ្តាលសតវត្សទី ១៩ ដែលមហាអំណាចបារាំងបានមកដល់កម្ពុជា គឺក្នុងរយៈកាលជាង ៧០០-ឆ្នាំ ។ សង្គ្រាមផ្ទៃក្នុងបានបណ្តាលការកាប់សម្លាប់គ្នា និង កំទេចបំផ្លាញគ្នាទៅមកយ៉ាងខ្លាំងជានិច្ច ។ រីឯសង្គ្រាមបរទេស នៅពេលគេមានជោគជ័យ វាបានបណ្តាលមហន្តរាយរឹតតែធំទៀត គឺក្នុងគ្រប់វិស័យទាំងអស់ព្រមទាំងធនធានមនុស្ស(អ្នកចេះដឹង អ្នកមានបច្ចេកទេសខ្ពស់ៗ...) ដែលត្រូវគេសម្លាប់ចោល ឬ កេណ្ឌយកទៅបម្រើប្រទេសគេ ។

ក្រោយពីអង្គររលំទៅ រាជធានីខ្មែរដែលជាទីប្រជុំវប្បធម៌ និង ចំណេះវិជ្ជាសំខាន់ ៗ ត្រូវបានផ្លាស់ប្តូរទីកន្លែងឥតឈប់ឈរ ជាហេតុធ្វើឲ្យចំណេះវិជ្ជា និង វប្បធម៌ប្រពៃណីនោះ បាត់បង់អ្នកថែរក្សា ហើយរលេះរលស់ និង សាបរលាបបន្តិចម្តង ៗ ថែមទៀត ។ ដោយសារតែមហន្តរាយរាប់រយឆ្នាំជាបន្តបន្ទាប់នេះ មនុស្សខ្មែរបានធ្លាក់ខ្លួនក្រតោកយ៉ាក សឹងតែរកអ្វីហូបមិនបាន រកអ្វីជ្រកនៅ ឬ ស្លៀកពាក់មិនបាន ហើយត្រូវរស់ដូចសត្វធាតុ ។ នេះហើយជាបុព្វហេតុធំ ៗ នៃការភ្លេចភ្លាំង និង បាត់បង់នូវក្បួនខ្នាតនៃប្រពៃណី និង ទំនៀមទម្លាប់ល្អរបស់ជាតិសាសន៍ខ្មែរ ។ ជាមួយគ្នានេះ បរទេសដែលគេមានជោគជ័យ ហើយមកត្រួតត្រាខ្មែរ គេតែងនាំមកនូវរបៀបរបបរស់នៅ និង ផលិតកម្មរបស់គេ ឬ ដែលគេយករបស់ខ្មែរទៅកែច្នៃ មកឲ្យខ្មែរទទួលវិញ ព្រោះតែខ្មែរ លែងស្គាល់តម្លៃនៃរបៀបរបប និង របស់របរខ្លួនទៅហើយ ។

ជាការធម្មតាទេ មនុស្សអត់ឃ្លាន ក៏ដូចគ្នានឹងមនុស្សអវិជ្ជា គេលែងមានសីលធម៌ជាប់នឹងខ្លួនហើយ ។ មនុស្សលោភលន់អំណាច (នៅសម័យណាៗក្តី) ក៏ដូចនេះដែរ គឺគេមានតែគំនិតស្មារតីសាហាវឃោរឃៅដណ្តើមយកអំណាចដើម្បីលួចប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ឬ សម្បត្តិជាតិប៉ុណ្ណោះ ។ ជាពិសេសចាប់ពីក្រោយសម័យលង្វែក មកដល់បច្ចុប្បន្នកាលនេះ អ្នកដឹកនាំកំពូលនៃស្រុកខ្មែរច្រើនណាស់ ជាមនុស្សអវិជ្ជា ដែលបានឡើងកាន់អំណាច ដោយសារការកាប់សម្លាប់ លួចធ្វើឃាត អ្នកដឹកនាំមុន ឬដោយសារគុណបរទេស ដែលមានជោគជ័យ ហើយលើកតម្កើងខ្លួន ឲ្យ

ភ្លេតភ្លាំងជំនួសគេលើប្រជារាស្ត្រខ្មែរ ដូចជាសព្វថ្ងៃគឺធ្វើឲ្យប្រជារាស្ត្រខ្មែរនៅតែក្រតោកយ៉ាក និង ល្ងិតល្ងង់ជានិច្ច ឬ ក៏មានការចេះដឹងបន្តិចបន្តួចមិនឲ្យជ្រៅជ្រះឡើយ ។

ដោយហេតុតែពួកអ្នកដឹកនាំ មិនដឹងយល់អំពីវប្បធម៌ និង ប្រពៃណីនៃជាតិសាសន៍ខ្លួន ក៏ពួកប្រជារាស្ត្រត្រូវរស់តែក្នុងវប្បធម៌បរទេស ហើយលែងជឿលើវប្បធម៌ជាតិឯង ភាសាជាតិឯង លែងជឿលើគ្នីគ្នាឯង និងលើខ្លួនឯងតែម្តង ។ អ្នកខ្លះ លែងទាំងចង់និយាយភាសាខ្មែរផង លែងហ៊ានប្រាប់គេ ថា - ខ្លួនជាជាតិសាសន៍ខ្មែរ ព្រោះខ្លាចគេថាខ្លួនជាមនុស្សថោកទាប ។ ប៉ុន្តែ នេះ ក៏ជាបុព្វហេតុមួយនៃសង្គ្រាមដែរ ព្រោះវានៅតែ មានជនជាតិខ្មែរមិនចូលចិត្តរបៀបរស់នៅ និង ការភ្លេតភ្លាំក្នុងគ្រប់វិស័យ នៃបរទេស ហើយងើបប្រឆាំង និង វាយប្រហារទៅវិញជានិច្ច។

នេះ ជាវង្វង់មហន្តរាយ ដែលគ្មានផ្លូវចេញទេ ដរាបណាខ្មែរទូទៅ មិនប្តេជ្ញាដាច់ខាត ថាត្រូវតែវិលទៅប្រកាន់ និង គោរពក្បួនខ្នាតវប្បធម៌ និង ប្រពៃណីនៃការអប់រំល្អនៃពូជអំបូរខ្មែរទេ ។

សូមជម្រាបថា យើងខ្ញុំមិននិយាយអួត មិននិយាយធ្មេចភ្នែកទេ... យើងបើកភ្នែកឃើញច្បាស់ហើយ ទើបនិយាយ និយាយប្រាប់ និយាយដាស់បងប្អូនខ្មែរ ឲ្យយល់ឲ្យភ្ញាក់រលឹកឡើង ។ ខ្មែរយើងពីដើម (ក្នុងអតីតកាល) មានពូជគឺមានវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ ការអប់រំ ល្អខ្ពង់ខ្ពស់ណាស់ សូម្បីតែបរទេស ក៏គេកោតសរសើរខ្មែរយើងដែរ ។ ប្រទេសជិតខាងយើង គេទើបនឹងចាប់កសាងវប្បធម៌ក្នុងពេលថ្មីៗនេះទេ ។

ឯកំហុសឆ្គងខ្វះ និង កង្វះខាត ជាការធម្មតាទេ មិនមែនតែខ្មែរទេ ជាតិណាៗក្នុងលោក ក៏មានកំហុសឆ្គង និង កង្វះខាត ដូចគ្នាដែរ ។ កំហុសឆ្គង ត្រូវតែកែលំអ កង្វះខាត ត្រូវតែស្វែងរកបន្ថែម ។ អ្នកលួចជាតិ អ្នកបំផ្លាញជាតិ អ្នកក្បត់ជាតិ អ្នកបម្រើបរទេស ។ល។ វាជាបុគ្គល ឬ មនុស្សមួយក្រុមតូច មិនចាត់ទុកជាពូជរបស់ខ្មែរទេ ព្រោះខ្មែរភាគច្រើនណាស់ គេមិនធ្វើដូចពួកវាទេ ។ តាមច្បាប់ អ្នកមានកំហុសត្រូវតែមានទោស គឺត្រូវតែយកមកអប់រំ ឬ ធ្វើទោសតាមកំហុសនោះ ។ និងទុកជាមេរៀន កុំឲ្យមានមនុស្សធ្វើខុសដូចនោះតទៅទៀត ។

សូមបងប្អូនខ្មែរទាំងអស់គ្នា ឈប់ឈ្លោះទាស់ទែងគ្នា ត្រូវរាប់អានគ្នា ត្រូវជួយគ្នា ត្រូវស្រឡាញ់វប្បធម៌ និង ប្រពៃណីល្អរបស់ខ្មែរយើង ហើយសាមគ្គីគ្នាកសាងជាតិខ្មែរយើង ឲ្យថ្កុំថ្កើងរុងរឿងឡើងវិញ តទៅទៀត ៕

# ពូជ គឺ គំនិត

៙✵៚

| | |
|---|---|
| *ពូជ គឺ គំនិត និង ចំណេះ* | *វិជ្ជាវិសេសល្បីអស្ចារ្យ* |
| *កសាងប្រាង្គប្រាសាទសីលា* | *វប្បធម៌ថ្លៃថ្លា...ចរិយាខ្មែរ ។* |
| កូនចៅជាន់ក្រោយកុំព្រងើយ | របស់មានហើយត្រូវជួយថែ |
| ចេះកសាងខ្លួនខ្លាំងពូកែ | កុំឲ្យចាញ់គេជាតិដទៃ ។ |
| អ្វីដែលនៅខ្វះមិនទាន់មាន | ត្រូវតែខំរៀនគិតលកលៃ |
| ធ្វើឲ្យកើតឡើងទើបផុតភ័យ | ពឹងជាតិដទៃមិនស្រួលទេ ។ |
| អ្វីដែលមិនល្អឬមិនសម | ត្រូវតែកែផ្សំខំងាករេ |
| កែឆ្នៃឲ្យល្អមាំស្ថិតស្ថេរ | ពេញនិយមគេត្រូវការវិញ ។ |
| អ្វីដែលអាក្រក់ខូចប្រយោជន៍ | នាំឲ្យហិនហោចគ្មានចំណេញ |
| ត្រូវតែលះបង់វាចោលចេញ | ស្វែងរកថ្មីវិញកុំអាល័យ ។ |
| យើងកសាងជាតិត្រូវសាមគ្គី | រួបរួមមូលមីរថែតម្លៃ |
| វប្បធម៌ជាតិយើងឲ្យថ្លាថ្លៃ | នឹងនាំគ្នាឆ្នៃល្អតខ្ពស់ឡើង ។ |
| កុំឈ្លោះទាស់ទែងបាក់បែកគ្នា | ជាតិកម្ពុជាយើងមិនថ្កើង |
| មេត្តាករុណាគ្នាច្រើនឡើង | ទើបជាតិយើងថ្កើងឡើងវិញបាន ។ |
| បងប្អូនខ្មែរអើយភ្ញាក់រលឹក | គក្រេងគគ្រឹកកុំបីខាន |
| កសាងការពារជាតិឲ្យបាន | កម្ពុជាក្សេមក្សាន្តអង្វែងទៅ ៕ |

**ភិក្ខុ ខិន ភេន**

# កំណាព្យ

៙✵៚

ជាពាក្យរំលឹកដាស់តឿនខ្មែរ សេចក្ដីចប់ក្នុងឃ្លាក្រុមខ្លួន មិនបាច់មានចុងចួនទៅឃ្លាមួយទៀតទេ ។

✵✵✵

១-កុំស៊ីសប្បាយតែពួកគ្នាឯង ត្រូវចេះគិតក្រែងដល់ខ្មែរគ្រប់គ្នា
រាស្ត្រខ្មែរមានទុក្ខពេញកម្ពុជា ត្រូវតែជួយគ្នាឲ្យបានសុខផង ។

២-យកសម្បត្តិជាតិធ្វើសម្បត្តិខ្លួន គប់គិតនឹងយួនសត្រូវសួព្វជ
លក់លួចទ្រព្យជាតិវិនាសហិនហោច ជាពួកកំហូចក្បត់ជាតិផងខ្លួន ។

៣-កុំស៊ីច្រើនពេកប្រយ័ត្នបែកពោះ ក្ដើមិនពីរោះជាប់ដល់កូនចៅ
ជាតិស្គមរីងរៃរាស្ត្ររឹតតែក្ដៅ ទ្រាំលែងបានទៅប្រយ័ត្នតាយហោង ។

៤-ព្រោះតែរឿងស្រីអស់ទឹកដីជាតិ គំនិតមារយាទអន់ជាងតិរច្ឆាន
សត្វមិនដូរដីព្រោះស្រីកល្យាណ ដើម្បីឲ្យបាននំអាកោរគេ ។

៥-សំណូកសូកបាន់គិបកេងប្រវ័ញ្ចន៍ គេគាបចម្រាញ់សូម្បីអ្នកក្រ
ខ្លាខ្លះសព្វគ្រប់តាំងពីអង្ករ គួរតែមានធម៌មេត្តាគ្នាផង ។

៦-អ្នកស៊ីសំណូកទុកដូចជាក្បត់ ព្រោះមិនម៉ត់ចត់ខ្វះក្ដីស្មោះត្រង់
ត្រូវតែដេញចោលឬប្រហារបង់ ដើម្បីតម្រង់សង្គមជាតិយើង ។

៧-កុំអាងឮកែគេចពីច្បាប់រដ្ឋ តែគេចមិនផុតពីច្បាប់នៃកម្ម
ទោះបីអស់ពេលយូរអង្វែងឆ្នាំ គង់តែផលកម្មតាមទាន់ពុំខាន ។

៨-កុកភ្លេចគិតជង់ព្រោះចង់បានត្រី ជង់ដេកនៅដីឥតភ្លេចកុកទេ
បើកម្មមកដល់កុកអើយកុំរេ មិនរួចខ្លួនទេព្រោះមើលងាយជង់។

៩-ស្រឡាញ់យសសក្តិហើយនឹងប្រាក់មាស ភ្លេចអស់ខ្មែររាស្ត្រជាតិរបស់ខ្លួន
ចោលសាច់យកឆ្អឹងទៅពឹងសៀមយួន ពិតពុំរួចខ្លួនត្រូវភ្ជាក់រលីក ។

១០-ល្បែងអបាយមុខពាលាស្រាស្រី ល្បែងភ្នាល់អ្វីៗមិនល្អទាំងអស់
ត្រូវជៀសឲ្យឆ្ងាយកុំលេងឲ្យសោះ ព្រោះល្បែងអស់នោះនាំឲ្យហិនហោច។

១១-សុខចិត្តស្លាប់ខ្លួនកុំឲ្យជាតិស្លាប់ ទោះបីគេកាប់ដូចលោកសីនគុយ
រស់បំផ្លាញជាតិមានតែក្លិនស្អុយ ស្លាប់ដូចសីនគុយក្រអូបប្រោសខ្យល់។

១២-សុខចិត្តស្លាប់ខ្លួនកុំឲ្យជាតិស្លាប់ តស៊ូចាក់កាប់ទាំងក្មេងទាំងចាស់
មិនត្រូវសុំរស់ធ្វើខ្ញុំកញ្ជះ ថោកទាបខ្មាំងណាស់ស្លាប់ប្រសើរជាង។

១៣-បើជាតិយើងរស់អ្វីៗក៏រស់ បើជាតិយើងអស់អ្វីៗក៏ស្លាប់
វប្បធម៌សាស្នាគង់តែឱនអាប់ មិនយូរមិនឆាប់ស្លាប់អស់រលីង ។

១៤-ស្រឡាញ់ជាតិខ្មែរត្រូវតែការពារ លះទ្រព្យនានាសូម្បីជីវិត

ឲ្យតែជាតិរស់ខ្លួនឯងសុខចិត្ត　សូម្បីជីវិតក៏ហ៊ានពលី ។

១៥-ស្រឡាញ់ជាតិខ្មែរត្រូវថែវប្បធម៌　កេរតំណែលល្អតពីដូនតា
ទប់ទល់វប្បធម៌បរទេសពាលា　យើងកុំនាំវាចូលមកស្រុកយើង ។

១៦-ស្រឡាញ់ជាតិខ្មែរត្រូវថាខ្លួនខ្មែរ　កុំខំគេចកែថាសែចិនយួន
ពួកស្អប់ម្លូកណាស់ស្រឡាញ់តែដូន　យើងត្រូវភ្ញាក់ខ្លួនទាត់វាចោលទៅ។

១៧-ស្រឡាញ់ជាតិខ្មែរត្រូវតែខំគិត　កែឆ្នៃប្រឌិតខំគិតជានិច្ច
គិតហើយខំធ្វើមិនដែលមានភ្លេច　ខ្មែរល្បីល្បួលេចព្រោះគិតធ្វើល្អ ។

១៨-ស្រឡាញ់ជាតិខ្មែរត្រូវនិយមខ្មែរ　កុំគិតងាកបែររកតែបរទេស
ទុករបស់ខ្មែរឲ្យនៅក្រៀមផ្អេះ　អំពើបែបនេះមិនសមជាខ្មែរ ។

១៩-ស្រឡាញ់ជាតិខ្មែរកុំសាងអាក្រក់　អ្វីនាំឲ្យល្អក់សៅហ្មងជាតិយើង
សាងតែរឿងល្អបវរថ្កុំថ្កើង　កេរ្តិ៍ឈ្មោះរុងរឿងសាយសព្វទិសា។

២០-រឿងអាក្រក់ចាស់ត្រូវបំបាត់ចោល　កុំយកមកពោលមកបដិបត្តិ
កប់វាឲ្យជ្រៅទុកនៅស្ងៀមស្ងាត់　យូរទៅរសាត់បាត់បង់ទៅឯង ៕

**ភិក្ខុ ខិន គេន**

# លោកអ្នកសប្បុរស ដែលបានជួយឧបត្ថម្ភការបោះពុម្ព

១-លោក អាន តាត្រីម និង ភរិយា
(ទិញម៉ាស៊ីនដេរសៀវភៅ)........................៥០០ €
២-លោក យៀង និង ភរិយា
(ទិញម៉ាស៊ីនដេរសៀវភៅ)........................ ១០០ €
៣-លោក ខេង នៅ លោកស្រី តែ ចាយ ១០០ €
៤-លោក ទា ឡឹកឆាយ ៥០ €
៥-លោក ង៉ី ហុក និង ភរិយា ២០ €
៦-លោកស្រី ឡោត គីរីកញ្ញា និង អេឌ័រ ៥០ €
៧-គ្រួសារ ណុប ពុទ្ធិរី ២០ €
៨-ឧបាសក ណៃ ហួរ ២០ €
៩-អាចារ្យ មិន ធូ ឧបាសិកា តាំង រួចហ៊ៅ ២០ €
១០-ឧបាសិកា គុល ទូច ៥០ €
១១-ឧបាសិកា ឡាយ រុំ ៣០ €
១២-ឧបាសិកា នេត្រ គួន ២០ €
១៣-ឧបាសិកា សុក គ្រី ២០ €
១៤-លោក ទី លន់ និង ឈរ ខេង គីម ៥០ €
១៥-ឧបាសក តាន់ ណាំ ឧបាសិកា លិម ឆេងអ៊ី ៥០ $
១៦-ឧបាសក ឡេង ប៊ុនស៊ាង ឧបាសិកា ជិន សាត ៥០ €

១៧-ឧបាសិកា ស៊ីសុវត្ថិ ក្រិត្យនារី ៣០ €

១៨-ឧបាសិកា ឈា ឡេងហាក់ ២០ €

១៩-លោក លិម ហ៊ុយគៀង អ្នកស្រី ម៉ៅ ទៀង ៥០ $

២០-លោក ខេង វេងស៊ាន និង យឹម វីនី ២០ €

២១-ឧបាសិកា ម៉ា វណ្ណា និង បុត្រធីតា ២០ €

២២-ឧបាសិកា នៅ ទាវខេង និង បុត្រធីតា ២០ €

២៣-ឧបាសិកា ណែម លិមអ៊ាន ២០ €

២៤-ឧបាសិកា ណែម លិមអ៊ុន ២០ €

២៥-លោក ខៀវ ឡេង និង ភរិយា ២០ €

២៦-លោក និង លោកស្រី តាវ ឃុនហ៊ាង ២០ €

២៧-ឧបាសិកា ឈា ឆេងលន់ ២០ €

២៨-ឧបាសិកា ឃី អេងឡាំ ២០ €

២៩-ឧបាសិកា អ៊ឹង អាង ២០ €

៣០-ឧបាសិកា ចាន់ ណាត ១៥ €

៣១-ឧបាសិកា អៀង ហុង ១៥ €

៣២-ឧបាសិកា ប៊ុន ហ៊ុលឃុត ១៥ €

៣៣-ឧបាសិកា ប៉ែ លិន ១៥ €

៣៤-ឧបាសិកា ឃិន ហុកទីវ ១៥ €

៣៥-ឧបាសិកា សុត សុផានី ១៥ €

៣៦-ឧបាសិកា អាត អេង ១៥ €

៣៧-ឧបាសិកា ស៊ាប គីមហ៊ាង ១៥ €

៣៨-ឧបាសិកា គួ អៀនី ១៥ €

៣៩-ឧបាសិកា ជូ ម៉ាក់ ១៥ €

៤០-ឧបាសិកា ប៊ូ ដាណារ៉េត ១៥ €

៤១-ឧបាសិកា អ៊ុំង ម៉ាឡេង ២០ €

៤២-ឧបាសិកា ឈុន ស៊ីវហ៊ាង ១៥ €

៤៣-ឧបាសិកា តាំង អ៊ីម ១៥ €

៤៤-ឧបាសិកា កឹម សូផន ១៥ €

៤៥-ឧបាសិកា ហុង ងិន និង នាង តង ៥០ €

៤៦-ឧបាសិកា ទី វណ្ណហង្ស ១៥ €

៤៧-ឧបាសិកា សេក ហេង ១៥ €

៤៨-លោក យុន សារុន ២០ €

៤៩-លោក ដារ៉ា ២០ €

៥០-លោក ជួន ទីម អ្នកស្រី ទិត ពៅ ២០ €

៥១-លោក អ៊ុន សារ៉េន និង ភរិយា ១៥ €

៥២-ឧបាសិកា សួស សុភាព និង បុត្រធីតា ២០ €

៥៣-ឧបាសិកា គាត ស្សូរី ២០ €

៥៤-ឧបាសក សី សួម ឧបាសិកា ចក ញ៉ិយ ២០ €

៥៥-លោកស្រី ប៊ុន ហ៊ុនគី ២០ €

៥៦-អ្នកស្រី គិម មួយ ២០ €

៥៧-ឧបាសិកា តាំង គុយអេង ១៥ €

៥៨-លោក និង លោកស្រី សួង ណារឿន ២០ €

៥៩-លោកស្រី ឆាវ ភីន ព្រមទាំងបុត្រ ៣០ €

៦០-អ្នកស្រី ចៅ សាវុទ្ធី ព្រមទាំងបុត្រ ៣០ €

៦១-ETIENNE LAY ២០ €

៦២-លោក ជា យានហុង ១០ €

៦៣-លោក ធុច រតនា ៣០ €

៦៤-លោក និង លោកស្រី ម៉ែន សាភ័ត និង អ៊ុង យុត្ថា ២៥ €

៦៥-លោកស្រី ជាវ ស៊ីវ ហ្សង ២០ €

៦៦-លោកស្រី ជាវ អួន ២០ €

៦៧-ឧបាសិកា អ៊ុំ យន ២០ €

៦៨-អ្នកស្រី ប៉ាត់ គីមហ៊ាង ១០ €

៦៩-ធៀម សុភាព ១៥ €

៧០-Mme NGO CHUNTEK ២០ €

៧១-ទា គីម លី ៥០ €

៧២-ទា គីម លន់ ៣០ €

៧៣-ឃុន ឆេង ស៊ីម ២០ €

៧៤-ឃុន រត្នម៉ាលី ២០ €

៧៥-ម៉ារី រត្នម៉ាលី ១០ €

៧៦-លោក និង លោកស្រី ស៊ាម ហ៊ុច ១៥ €

៧៧-លោក និង លោកស្រី ភៀវ ម៉ារី និង បុត្រធីតា ១៥ €

៧៨-លោក ទេព សំផន និង ភរិយា ២០ €

៧៩-ឧបាសក ឡៅ ហេង ឧបាសិកា តាន់ សាយយុត ១៥ €

៨០-អ្នកស្រី ឡៅ សាយ ឃីម ១៥ €

៨១-អ្នកស្រី ជីប ហុងយ៉េន ១៥ €

៨២-លោក ផុង ហុងកៅ អ្នកស្រី ឡៅ ហុងឡាយ ១៥ €

៨៣-អ្នកស្រី ឡៅ ហុងស៊ីម និង បុត្រធីតា ១៥ €

៨៤-ផុង សួនីថា និង ស៊ុន ណារ៉េត ១៥ €

៨៥-ឧបាសិកា ញ៉ឹក សាយ៉ាន់ ១៥ €

៨៦-ឧបាសិកា ហូ គីមឡេង ១៥ €

៨៧-លោក សាគូ សាមុត និង គ្រួសារ ១៥ €

៨៨-លោក ភឿង ម៉ាលីរិទ្ធ និង ភរិយា ១០ €

៨៩-អ្នកស្រី ភឿង ពិសី និង គ្រួសារ ១០ €

៩០-អ្នកស្រី មុំ ភិណ្ណារី និង គ្រួសារ ២០ €

៩១-អ្នកស្រី មុំ អូនី និង គ្រួសារ ១០ €

៩២-លោក និង លោកស្រី ថោង ស៊ីម៉ុង ១០ €

៩៣-លោក និង លោកស្រី ប៊ូ ផាត ១០ €

៩៤-អ្នកស្រី ប៉ាវ សារ៉េន និង ធីតា ២០ €

៩៥-លោក និង អ្នកស្រី ឱម ស៊ីថា ១៥ €

៩៦-អាចារ្យ ញាណ ឆាន និង ភរិយា ១៥ €

៩៧-លោក ខូវ ឡាយអាន អ្នកស្រី គីម តុន ២០ €

៩៨-ឧបាសិកា តឹក ឡាយ (ហៅពៅ) ១០០ $

៩៩-ភិក្ខុ ងិន ភេន ២០ €

យើងខ្ញុំ សូមឧទ្ទិសចំណែកបុណ្យកុសលនេះ ចំពោះលោក អ្នក ដ៏មានគុណទាំងឡាយ មានគ្រូឧបជ្ឈាយាចារ្យ និង មាតាបិតា ជាដើម ព្រមទាំងញាតិមិត្រទាំងឡាយ ។ សូម លោក អ្នក ដ៏មានគុណទាំងឡាយជាដើមនោះ អនុមោទនាចំពោះបុណ្យកុសលនេះ ហើយទទួលនូវឥដ្ឋមនុញ្ញផលជាទីគាប់ចិត្ត កុំបីអាក់ខានឡើយ ៕

# ស្រឡាញ់ពូជខ្មែរ

៙✺៚

ស្រឡាញ់ពូជខ្មែរត្រូវថែរក្សា    កេរពីដូនតាទុកឲ្យគង់វង់
ដែលលោកខំសាងដោយក្តីផ្ចិតផ្ចង់    មិនឲ្យបាត់បង់ត្រង់ណាមួយសោះ ។
ស្រឡាញ់ពូជខ្មែរត្រូវថែរក្សា    អ្នកមានបញ្ញាចេះដឹងឥតខ្ចោះ
គេបានសិក្សាសព្វសីល្ប៍ទាំងអស់    លោកអ្នកប្រាជ្ញនោះជួយសាងជាតិយើង។
ស្រឡាញ់ពូជខ្មែរត្រូវថែរក្សា    នគរវត្តភ៌ាឲ្យចំរើនឡើង
ទៅទន្ទឹមគ្នាទាំងពីររុងរឿង    ប៉ុន្តែពួកយើងទុកជាតិជាធំ ។
ស្រឡាញ់ពូជខ្មែរត្រូវថែរក្សា    ធម៌ ៤ ប្រការលោកហៅថាព្រហ្ម
ទោះបីអ្នកតូចឬមួយអ្នកធំ    ត្រូវមានធម៌ព្រហ្មវិហារធំផុត ។
ស្រឡាញ់ពូជខ្មែរត្រូវថែរក្សា    អប់រំបញ្ញាចិត្តថ្លាបរិសុទ្ធ
ដឹងខុសដឹងត្រូវបញ្ញាភ្លឺមុត    អាចនាំឆ្លងផុតក្តីទុក្ខក្តួលក្តៅ ។
ស្រឡាញ់ពូជខ្មែរត្រូវថែរក្សា    ទម្លាប់ដូនតាបំបួសកូនចៅ
អប់រំឲ្យឆ្អិនកុំឲ្យនៅឆៅ    ពេលប្រើការទៅបានផលប្រចក្ស ។
ស្រឡាញ់ពូជខ្មែរត្រូវថែរក្សា    និយមអាហារសំលៀកបំពាក់
និងប្រពៃណីថ្ងៃថ្លាអនគ្ឃ    ខ្មែរត្រូវរួមរក្សាទុកឲ្យល្អ ។
ស្រឡាញ់ពូជខ្មែរត្រូវថែរក្សា    រួមជាតិខេមរាឲ្យមូលកុះករ
នាំគ្នាសាងជាតិឲ្យថ្កើងបវរ    ល្បីដូចអង្គរខ្ចាយខ្ចរគ្រប់ទិស ៕